# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---

ឆ្នាំទី ២៥ ខែមេសា លេខ ៤

ព.ស. ២៤៩៥ – គ.ស. ១៩៥៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំនឿខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — អត្ថបេមកថា ............... | ព្រះមហាទេព- ឡុច ........ | ២៤៤ |
| — កឋិនកថា (តមក) ............. | ព្រះមហាឧត្តមវិជ្ជាកែ - អៀន ... | ២៥១ |
| — សេចក្ដីល្អ - សេចក្ដីអាក្រក់ ....... | លោក ស៊ុន - ហ៊ាន ....... | ២៥៩ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — ការបណ្ដុះនិស្ស័យ (តមក) ....... | ព្រះមហាឧត្តមវិជ្ជា ប៉ុង - ប៉ម ... | ២៦៥ |
| — រឿងសាមកុក (តមក) .......... | ឧកញ៉ា ទូ - កន ......... | ២៧១ |
| — រឿងអារ័ក្សថ្លែងរឿងម្ដែប្រាំ (តមក) ... | លោក វ៉ាយ - ប៊ុក ........ | ២៧៦ |
| — រឿងស្លាប់ព្រោះជាតិ (តមក) ....... | លោក គង់ — លឹម ........ | ២៨៥ |
| — រឿងប៉ូលនឹងវីរ័ស៊ីនី (តមក) ....... | លោក ផេង - ជ្រីវ ........ | ២៩០ |
| **កំណត់ទីនប្រវត្តិការណ៍** | | |
| — សន្និសិទព្រះពោធិវង្ស ហួត - តាត អំពីសមាជសាកលលើកទី ២ នៃពុទ្ធសាសនា | (តមក) ពុទ្ធសាសនបណ្ឌិត្យ ... | ២៩៥ |
| — សុន្ទរកថាបណ្ឌិតម៉ាលាល់ៈសេកេរៈថ្លែងក្នុងសមាជសាកលលើកទី ២ នៃពុទ្ធសាសនា | (តមក) ពុទ្ធសាសនបណ្ឌិត្យ ... | ៣០១ |
| — ពិធីប្រឡងធម្មវិន័យ នៅវត្តព្រះព្រហ្មរតន៍ខេត្តសៀមរាប ............ | ព្រះមហាឧត្តមវិជ្ជា កែ-អៀន ... | ៣០៦ |
| — បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) | ក្រសួងធម្មការ .......... | ៣១៩ |


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៩២រ. ០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


| PARTIE RELIGIEUSE | | Pages |
|---|---|---|
| — Attapemakatha ........... | Brah Maha LE-LACH ..... | 244 |
| — Kathinakatha............ | Brah Maha Ker-œurn ..... | 251 |
| — Bonne action - mauvaise action | M. SIN-HEAN ......... | 259 |
| **PARTIE LITTERAIRE** | | |
| — Education morale (suite).... | Vén. Pœung-Pam ..... | 265 |
| — Histoire de SAMKOK (suite).. | Oknha Nou-Kan ....... | 271 |
| — Les vingt cinq récits du Mauvais Génie (suite)......... | M. Ray-Buc ......... | 276 |
| — Mort pour la patrie (suite) ... | M. Kong-Lim .......... | 285 |
| — Paul et virginie (suite) ..... | M. Phéng-Chrieu ........ | 290 |
| **NOTES ET CHRONIQUES** | | |
| — Conférence du Vén. Brah Bodhivangs HUOT-TATH sur le 2e Congrés Mondial Bouddhique (suite)................. | Institut Bouddhique ..... | 295 |
| — Discours du Dr MALALASEKERA au 2e Congrés Mondial Bouddhique............... | — — ...... | 301 |
| — Cérémonie d'examen du Dhammavinaya à la pagode de Brah Brahmaratana-Siemreap....... | Brah moha KER-ŒURN ... | 306 |
| — Nomination des nouveaux Chau-adhikar suite ........ | Ministère des Cultes ...... | 319 |


Prix d'abonnement annuel comprenant 12 numéros : 192$00

# សព្ទសាធុការពរឆ្នាំថ្មី

## ព. ស. ២៤៩៦

---

ឆ្នាំម្សាញ់ បញ្ចស័កស័ក្តិពិសី    ព. ស. សោតថ្មីពីរពាន់បួន
រយទឹងកៅសិបប្រាំមួយជួន    សង្ក្រាន្តខ្មែរបួនចរចូលឋាន ។
ក្រុមពុទ្ធសាសនបណ្ឌិត្យ    ប្រសិទ្ធិ៍ពរថ្វាយ - ជូនសព្វឋាន
ដល់ជាតិសាសនា មហាក្សត្រក្សាន្ត    រដ្ឋខ្មែរឲ្យបានក្តីសុខា ៕
សូមព្រះភូមិន្ទបវរក្សត្រ    សោយរាជសម្បត្តិខ្ចាត់សោកា !
សូមក្រុមព្រះរាជញាតិវង្សា    មានមហេសក្កាលាភជ័យជោគ ! ។
សូមក្រុមព្រះសង្ឃទ្រង់សីលសុទ្ធ    និរទុក្ខចាកផុតភ័យក្នុងលោក !
សូមមានសាមគ្គីកុំបីស្មោក    ប្រយោគព្យាយាមលះកពប៉ ! ។
សូមព្រះរាជរដ្ឋាភិបាល    ជួរស្រាលកន្ទល់កលអប្រិយ
បំពេញកិច្ចការកេតផែនដី    ឲ្យមានសេរីក្តីសាន្តត្រាណ ! ។
សូមក្រុមនាហ្មឺនគ្រប់ក្រសួង    ធំតូចទាំងពួងអម្បាលម៉ាន
បានសុខចំរើនគ្រប់ៗប្រាណ    ស្មោះស្មានបំរើកម្ពុជា ! ។
សូមអស់បណ្តារាស្ត្រមជាតិ    របួតផុតឃ្លាតទុក្ខវេទនា
រីករាយសប្បាយពេញភាព    ក្រោមម្លប់រាជាវង្សវរ័ង ! ។

ពុទ្ធសាសនបណ្ឌិត្យ

# ព្រះមហាទៀ-ឡាប វត្តឧណ្ណមុនីរាម ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ កើត ខែបុស្ស
ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (៧-១-៤៩)

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ខ្ញុំព្រះករុណា សូមលើកកំបង់អញ្ជលីប្រណម្យ ចំពោះព្រះត្រៃរតន៍ដែលមានគុណប្រាកដដល់សត្វក្នុងត្រៃភព ដោយសេចក្ដីគោរព ជាសង្ខេបតែប៉ុណ្ណោះ ។

លំដាប់តពីបទនមស្សការនេះទៅ អាត្មាភាពនឹងដកស្រង់ព្រះពុទ្ធដីកាមួយកន្លែង ដែលមានក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ យកមកសំដែងដើម្បីថ្វាយដល់ទ្រង់ នឹងអស់លោក-អ្នក សាធុសប្បុរសទាំងឡាយ ដែលជាអ្នកទទួលមតិកគឺពុទ្ធឱវាទ ឧហាតពត់តម្រង់កាយវាចាចិត្តឲ្យបានស្លូតត្រង់ ជាគ្រឿងក្រេបជញ្ជក់យកនូវរសទាំងឡាយ មានអម្រឹតរសជាទីបំផុត ។ ព្រះពុទ្ធដីកានោះគឺ

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ

ប្រែថា "បើបណ្ឌិតដឹងខ្លួនថា ខ្លួនជាទីស្រឡាញ់របស់ខ្លួនហើយ ក៏គប្បីរក្សាខ្លួនទុកឲ្យល្អ គួរទំនុកបម្រុងខ្លួនទុកក្នុងវ័យទាំងបី វ័យណាមួយកុំខានឡើយ" ។

ពាក្យថាខ្លួនក្នុងភាសិតនេះបានដល់ធម្មជាតិពីរយ៉ាង គឺកាយ ១ ចិត្ត ១ ផ្សំបញ្ចូលជាមួយគ្នាហៅថាខ្លួន ។ ពួកមហាជនដែលបានកើតមកក្នុងសកលលោកសុទ្ធតែស្រឡាញ់ខ្លួនជាងអ្នកដទៃឬវត្ថុដទៃ សូម្បីមាសពេជ្រដែលគេនិយមថាជារបស់ប្រសើរបំផុត ក៏នៅតែមិនស្រឡាញ់ជាងខ្លួនឬស្មើនឹងខ្លួន, សមដូចពុទ្ធភាសិតក្នុងគម្ពីរសំយុត្តនិកាយថា នត្ថិ អត្តសមំ បេមំ "ស្រឡាញ់អ្វីស្មើនឹងខ្លួនឬជាងខ្លួនគ្មានឡើយ" ។ ដ្បិតថាពួកមហាជនដែលរកទទួលទាន ដោយកសិកម្មនឹងពាណិជ្ជកម្មមិនគិតដល់សេចក្តីលំបាកនឹងការហាលថ្ងៃហាលភ្លៀង ឬក៏ពួកក្រមនាម៉ឺនតូចធំ ដែលធ្វើការពេជការក្នុងមន្ទីរផ្សេងៗ ដោយចង់បានប្រាក់បៀវត្សក៏ព្រោះតែស្រឡាញ់ខ្លួន កុំថាឡើយតែមនុស្សដែលមានអវយវៈគ្រប់គ្រាន់ ដោយហោចទៅសូម្បីតែមនុស្សដែលអន្ធការមានខ្វាក់ខ្វិនកែ្វងក្ងជាដើម ក៏នៅតែស្រឡាញ់ខ្លួនឯងជាងអ្នកដទៃ ឬវត្ថុដទៃដែរ ។

បើបណ្ឌិតដឹងខ្លួនថាជាទីស្រឡាញ់ហើយ គួររក្សាខ្លួនទុកឲ្យល្អ ។ ឯការរក្សានោះមានពីរយ៉ាងគឺ រក្សាខ្លួនឲ្យជាប្រយោជន៍ក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ ។

១ – ការដែលសង់គេហស្ថាន មានប្រាសាទប្រាំពីរជាន់ជាដើម សម្រាប់ដេកអាស្រ័យនៅក្នុងលោកសន្និវាសនេះ ដែលជាគ្រឿងការពារនូវមូសសុច នឹងខ្យល់ថ្ងៃភ្លៀង ឬក៏រកថ្នាំសម្រាប់បំបាត់រោគដែលកើត

ឡើងក្នុងសរីរៈពាងកាយរបស់យើង ដូចជាអ្នកខ្លះហ៊ានចាយប្រាក់អស់រាប់ពាន់រាប់ម៉ឺន ឬ ជួលគ្រូពេទ្យមកឲ្យជួយព្យាបាលរោគ ក៏ព្រោះប្រយោជន៍ចំពោះខ្លួនរបស់គេ ៗ ប៉ុន្តែការរក្សានេះជាសេចក្តីរក្សាយ៉ាងតូចបានសេចក្តីសុខចំពោះបុគ្គលម្នាក់ៗ បើរក្សាឲ្យធំទូលាយទៅទៀត បានដល់ការរក្សាពួកក្រុមញាតិមិត្តសំឡាញ់ ឬក៏ពួកផ្តុំរួមគំនិតជាមួយគ្នាជួយរក្សាការពារទំនុកបំរុងប្រទេសជាតិមាតុភូមិរបស់ខ្លួន ឲ្យឡើងទៅកាន់ជាអារ្យៈប្រទេស ដូចជាប្រទេសគេជិតខាង ឈ្មោះថារក្សាយ៉ាងធំបំផុតចំពោះខ្លួនឯងផង ផ្សាយសេចក្តីសុខដល់អនុបុរសជាច្រើនទៅក្នុងអនាគតផង ៗ សេចក្តីដែលបានពណ៌នាមកខាងលើទាំងប៉ុន្មាននេះសុទ្ធតែជាការរក្សាសេចក្តីសុខក្នុងលោកនេះទាំងអស់ ៗ

២– បុគ្គលដែលខំផុសខាត់កំចាត់បង់នូវមន្ទិលគឺកិលេស ដែលជាគ្រឿងរួបរិតធ្វើចិត្តសត្វឲ្យសៅហ្មង ជាចំណងធ្វើបុគ្គលឲ្យវិលវល់ក្នុងភពទាំងបី ទាំងឧស្សាហ៍ធ្វើបុណ្យ មានការរក្សាសីល ៥ សីល ៨ ដើម្បីបន្ទោបង់នូវកិលេសយ៉ាងគ្រោតគ្រាត ជាហេតុរក្សាខ្លួនមិនឲ្យធ្លាក់ចុះទៅក្នុងអបាយភូមិមាននរកជាដើម នេះជាបដិបទាប៉ែកខាងគ្រហស្ថ ៗ បើប៉ែកខាងបព្វជិតវិញត្រូវរក្សាការពារកិរិយាមារយាទរបស់ខ្លួន ឲ្យសមរម្យតាមសមណភេទ គឺមានឥន្ទ្រិយសំវរៈក្នុងវេលាប្រែឥរិយាបថទាំង ៤ សមគួរតាមវិន័យបញ្ញត្តិ ព្រោះថាអ្នកបួសមិនត្រូវ

ប្រព្រឹត្តល្មើសនឹងព្រះវិន័យទេ ដ្បិតថាព្រះវិន័យជាភស្តុតាងរបស់អ្នកបួស បើអ្នកបួសគ្មានវិន័យជាវត្តប្រតិបត្តិ មុខជាក្លាយចិត្តពីអ្នកបួសឥតមានសង្ស័យឡើយ ម្ល៉ោះហើយទាយកទាយិកា អ្នកប្រាថ្នានូវបុណ្យកុសល សំគាល់តែគេទុកខ្លួនថាជាអ្នកបួសពិត ទំលះបង់នូវទ្រព្យសម្បត្តិ ដែលគេរកបានមកដោយសេចក្តីនឿយហត់ យល់ដាក់ក្នុងចិត្តថាជាបុញ្ញក្ខេត្តនឹងមានផលប្រយោជន៍តទៅខាងមុខ ត្រឡប់ទៅជាគ្មានផលប្រយោជន៍ ដូចជាគេយកទៅចាក់ចោលក្នុងទឹកទន្លេវិញ ។ សេចក្តីសង្ខេបដែលបានពោលមកខាងលើនេះជាអំពើអាក្រក់ បព្វជិតមិនត្រូវសន្សំទុកទេ ។ កាលបើអ្នកបួសប្រព្រឹត្តតាមព្រះវិន័យហើយ ឈ្មោះថាជាកុលបុត្រអ្នកទ្រទ្រង់ព្រះពុទ្ធសាសនា ធ្វើព្រះពុទ្ធសាសនា ឲ្យមានពន្លឺរុងរឿងឋិតថេរថេរកាលដរាបដល់គ្រប់ប្រាំពាន់ព្រះវស្សា នឹងជាឧបាយអាចរក្សាខ្លួនមិនឲ្យធ្លាក់ទៅកាន់កំណើតដ៏ថោកទាប មានកំណើតតិរច្ឆានជាដើមរមែងបានសោយសេចក្តីសុខ ក្នុងឋានសួគ៌នឹងព្រះនិព្វានជាទីបំផុតជាតិ ។ សេចក្តីទាំងប៉ុន្មាននេះ សុទ្ធតែជាការរក្សាខ្លួនក្នុងលោកខាងមុខ ។

ម្យ៉ាងទៀត គួរទំនុកបំរុងខ្លួនទុកក្នុងវ័យទាំងបី វ័យណាមួយកុំខានឡើយ ។ ឯការទំនុកបម្រុងខ្លួននោះមានពីរយ៉ាង គឺទំនុកបំរុងខ្លួនសម្រាប់លោកនេះ ១ សម្រាប់លោកខាងមុខ ១ ។

១ – កាលដែលយើងនៅក្នុងបឋមវ័យ គឺរាប់តាំងពីអាយុ ១ ឆ្នាំ ដរាបដល់អាយុ ៣៣ ឆ្នាំ ត្រូវទំសិក្សារៀនសូត្រលេខនព្វន្តអក្សរសាស្ត្រ

សម្រាប់ជាតិរបស់ខ្លួន  និងអក្សរសាស្ត្ររបស់ជាតិដទៃ  ឲ្យសមតាមកាលសម័យ ៗ ព្រោះថាមនុស្សយើង ដែលបានកើតមកក្នុងលោកមិនត្រូវធ្វើជាអ្នកល្ងង់ខ្លៅរកដម្រេះវិជ្ជាគ្មានទេ ៗ ការដែលគ្មានដម្រេះវិជ្ជានេះជាហេតុធ្វើខ្លួនមិនឲ្យមានពន្លឺរស្មី  ទាំងគិតអ្វីមិនសម្រេចដូចសេចក្តីប្រាថ្នា ៗ ធម្មតាមនុស្សល្ងង់តែងធ្វើខ្លួនឲ្យបានទទួលរងទុក្ខវេទនាឥតមានបន្ទោះ  បានជាពោលដូច្នេះព្រោះមនុស្សល្ងង់មិនដែលបានធ្វើធំទេ  មុខជានឹងនៅជាទាសគេអស់មួយជីវិតមិនខាន  នេះមិនមកពីអ្វីទេ  មកតែពីខ្វះការសិក្សារៀនសូត្រក្នុងសម័យដែលខ្លួនត្រូវរៀនសូត្រ  ចុះបើយើងជាអ្នកខំយកចិត្តទុកដាក់ក្នុងកិច្ចសិក្សារៀនសូត្រនូវដម្រេះវិជ្ជាផ្សេង ៗ  ឲ្យសមតាមវយៈកាលសម័យដែលលោកនិយម  មុខជាបានជួបប្រទះនូវផលប្រយោជន៍អ្វីមួយមិនខាន  ហើយនឹងបានទទួលយកនូវផលសន្តិសុខតទៅខាងមុខ  បើមិនបានធ្វើនាម៉ឺនតូចធំនឹងគេ  ក៏គង់ប្រកបកិច្ចការចិញ្ចឹមជីវិតដោយតម្រេះទោះ ៗ ដោយប្រពៃ  រមែងមិនធ្លាក់ខ្លួនទៅជាមនុស្សបម្រើគេដែរ ៗ

ឱយុវជនកុមារកុមារីទាំងឡាយ! ត្រូវក្រោកឡើង  ចូរខំស្វះស្វែងរៀនសូត្រឲ្យមែនទែន  ទាន់សម័យដែលខ្លួនអ្នកនៅក្មេង  ព្រោះការរៀននេះបានតែខ្លួនអ្នកកំពុងមានវ័យចម្រើន  មានសតិស្មារតីដ៏ក្លៀវក្លា  អាចរៀនទន្ទេញអ្វីចាប់ចាំមិនសូវភ្លេច ៗ បើចាំដល់មជ្ឈិមវ័យបច្ឆិមវ័យ  ដែល

យើងមានវ័យជាកណ្ដាលនិងចុងក្រោយបំផុតហើយ មិនងាយនឹងទ្រទ្រង់នូវអំពើនេះបានទេ មុខជាដេកសញ្ជប់សញ្ជឹងសោកស្ដាយដល់កិច្ចការនោះមិនលែងឡើយ ។ បើយុវជនក្មេងប្រុសស្រីទាំងអស់គ្នា ឃើញសេចក្ដីចំរើននិងសេចក្ដីវិនាសដូចពោលមកខាងលើនេះហើយ គួរតែអ្នកខំលះបង់នូវគំនិតខិលខូចនិងសេចក្ដីខ្ជិលច្រអូសចោលចេញ ហើយខំសេចក្ដីព្យាយាមខំប្រឹងប្រែងរៀនសូត្រ ទើបបាត់ថាជាអ្នកបេះទំនុកបម្រុងខ្លួនក្នុងលោកនេះ ។

២– ការដែលទំនុកបម្រុងខ្លួនប្រុងទុកក្នុងលោកខាងមុខនោះ គឺយើងត្រូវប្រើបញ្ញាចុះបញ្ចាំងមើលអត្តភាពរាងកាយនៃអាត្មា ឲ្យឃើញជាក់ច្បាស់ក្នុងចិត្តថា បញ្ចក្ខន្ធរបស់សត្វទាំងអស់ តែងមានសភាវៈប្រែប្រួលជានិច្ច ព្រោះសត្វដែលបានកើតមកក្នុងលោកទាំងអស់គ្នា រមែងធ្លាក់ចុះទៅក្នុងអនិច្ចំ ទុក្ខំ អនត្តា មានរូបពេលណា សុទ្ធតែជារបស់មិនទៀងទាំងអស់ តែងបានទទួលសោយនូវសេចក្ដីលំបាកកាយលំបាកចិត្តជាសភាវៈមិនឋិតក្នុងអំណាចរបស់ខ្លួន បើយើងឃើញដូច្នេះហើយ គួរខំព្យាយាមដុតបំផ្លាញនូវសេចក្ដីអាក្រក់ទាំងប៉ុន្មានដែលមានក្នុងខន្ធសន្តានកុំឲ្យកើតមានឡើង ហើយឧស្សាហ៍បំពេញនូវកុសលចរិយាជាឧបាយធ្វើចិត្តឲ្យបរិសុទ្ធ ផុតចាកសេចក្ដីសៅហ្មង ពោលគឺអកុសលធម៌ ។ កាលបើចិត្តយើងបរិសុទ្ធហើយ រមែងមិនមានវិប្បដិសារី គឺមិនមាន-

សេចក្តីក្តៅក្រហាយ ដោយឧបសគ្គនានាផ្សេងៗ មានតែសេចក្តីសុខសប្បាយរីករាយជានិច្ចសព្វកាលទាំងពួង, ទើងជាគុណជាតិដ៏សំខាន់បំផុត សម្រាប់ស្ទួយអត្តភាពរាងកាយរបស់យើង មិនឲ្យក្លាយទៅការកំណើតដ៏ថោកទាប មានកំណើតតិរច្ឆានជាប្រធាន ព្រោះយើងទាំងអស់គ្នា សុទ្ធតែជាអ្នកស្អប់ខ្ពើមកំណើតថោកទាបនោះក្រៃពេក មិនដែលនរណាមួយប្រាថ្នានូវកំណើតនោះសោះឡើយ ។

បើនរជនណា បានលះបង់នូវសេចក្តីអាក្រក់ ហើយខំបំពេញនូវសេចក្តីល្អបរិសុទ្ធ ដូចបានសំដែងមកនេះ ឈ្មោះថាជាអ្នកទំនុកបម្រុងខ្លួនទុកក្នុងលោកខាងមុខ ។

សំដែងមកក្នុងការស្រឡាញ់ខ្លួននឹងសេចក្តីថែរក្សាខ្លួន ព្រមទាំងការទំនុកបម្រុងខ្លួន ក៏អស់សេចក្តីតែប៉ុណ្ណេះ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ

ដោយអំណាចនៃធម្មទេសនានេះ សូមផ្សាយមេត្តាចិត្ត ដល់ជនទាំងឡាយទាំងពួងក្នុងលោកទាំងមូល បើសត្វបុគ្គលឯណាដល់ហើយនៅសេចក្តីទុក្ខ សូមឲ្យជាអ្នកបាត់ទុក្ខទៅ ! ដែលដល់ហើយនូវភ័យសូមឲ្យជាអ្នកបាត់ភ័យទៅ ! ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាអ្នកបាត់សេចក្តីសោកទៅ ! ។

# កឋិនគាថា

របៀបទេសនា បុច្ឆា-វិសជ្ជនា

ព្រះមហាឧត្តមវិជ្ជា កែ-អឿន វិរិយប្បញ្ញោ

វត្តព្រះព្រហ្មរតន៍ ខែត្រសៀមរាប រៀបរៀង

ព្រះទេពសត្ថាស្សូរ-ហាយ ពិនិត្យកែតម្រួល

(តមក)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះប្រជុំ ៣ នៃព្រះរតនៈ គឺព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ដោយសេចក្ដីគោរព ។

ឥមិនាបិ បណាមេន សទា សោត្ថី ភវន្តុ វោ

ដោយកិរិយាប្រណម្យប្រាយបង្គំ ចំពោះគុណព្រះរតនត្រ័យនេះឯង សូមសិរីសួស្ដីចំរើនដល់ពុទ្ធបរិស័ទទាំងឡាយ ឲ្យបានសព្វ ៗ កាល រៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

ឥតោ បរំ តអំពីបទនមស្ការនេះទៅ នឹងបានសំដែងព្រះសទ្ធម្ម-វិសេសទេសនា ជារបៀបបុច្ឆា-វិសជ្ជនា អំពីកឋិនទាន ព្រមទាំង អានិសង្សនៃកឋិនទាន; តែមុននឹងសំដែងនេះ សូមសន្មតតំខណិកនាម ទៅវិញទៅមកសិន ចំណែកអាត្មាភាពខាងណោះ គួរបាននាមថាជា

"មហាថេរៈ" ដោយមានវស្សាច្រើនជាង, ចំណែកលោកម្ចាស់ខាងណោះត្រូវបាននាមជា "អនុត្ថេរៈ" ដោយមានវស្សាតិចជាងអាត្មាភាព ។

អនុត្ថេរៈ ម្នាលអនុត្ថេរ! សូមលោកម្ចាស់ជួយ ដម្រង់ស្មារតីផ្ទៀងសោតប្រសាទចាំស្ដាប់ខ្ញុំនឹងបុច្ឆាសួរក្នុងកាលឥឡូវនេះ ។

១.- ម្នាលអនុត្ថេរ! អ្វីដែលហៅថា កឋិន? សូមនិមន្តវិសជ្ជនាមកមើល ។

ភន្តេ មហាថេរៈ បពិត្រមហាថេរដ៏ចំរើន! ដំណើរការណ៍ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងបញ្ញត្តរួមនូវរូបធម៌ និងនាមធម៌ទាំងឡាយបានឈ្មោះថា កឋិន, នឹងបានឈ្មោះថា កឋិន ដោយបរមត្ថធម៌ក៏ទេ, ពាក្យថា កឋិន ជាធម៌ឯកដោយវិសេសប្លែកជាងទានទាំងពួង ហៅថា កឋិន, សូមទានប្រាប ។

២.- សាធុ សាធុ ម្នាលអនុត្ថេរ! ចុះកឋិន-សព្ទនេះ បើប្រែតាមធាតុ បានសេចក្ដីដូចម្ដេច? បើប្រែតាមអត្ថជាដូចម្ដេច? សូមនិមន្តប្រែមកហើយអធិប្បាយឲ្យល្មមខ្ញុំស្ដាប់បានផងមើល ។

- បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណានឹងប្រែតាមធាតុ រួចប្រែតាមអត្ថ ទោះបីល្មមស្ដាប់បានឬពុំបាននោះមិនអាចធានាទេ ។ កឋិន សព្ទនេះបើប្រែតាមធាតុ អដ្ឋកថាប្រាប់ថា ធាតុដើមជា "កឋ" ប្រព្រឹត្តទៅក្នុងអត្ថពីរយ៉ាង ថា "កិរិយារស់នៅដោយក្រ" ១ ថា "កិរិយាពោល

សារសើរ" ១; ឯអត្ថថា "រស់នៅដោយក្រ" នោះ ដូចឈើស្នឹងដែលបុគ្គលកាត់យកឈើស្រស់មកបោះធ្វើជាស្នឹង ឯឈើស្នឹងនោះរស់ដុះលូតលាស់ឡើងបានដោយក្រពេក មានសេចក្ដីឧបមាយ៉ាងណា ឯកឋិនទានដែលទឹងកើតឡើងតាំងឡើងពេញទីជាកឋិនបានដោយក្រពន់ពេក មានឧបមេយ្យដូច្នោះដែរ ។ ចំណែកអត្ថថា "ពោលសារសើរ" នោះ គឺត្រូវទានដ៏វិសេសដែលព្រះអរិយបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើមតែងពោលសារសើរថា "មានផលដ៏វិសេស សម្រេចដល់បុគ្គលទាំងពីរខាង គឺខាងទាយកអ្នកឲ្យក៏បានអានិសង្សច្រើន, ខាងបដិគ្គាហកភិក្ខុអ្នកទទួលក្រាលកឋិនទឹងបុគ្គល គណៈ ឬសង្ឃដែលអនុមោទនាក៏បានសម្រេចអានិសង្សទាំង ៥ ពេញទីដល់អស់កឋិនក្ខេត្ត" ។ កឋិន-សព្ទនេះ បើប្រែតាមអត្ថដ៏សេចក្ដីមានពីរយ៉ាង ថា "កាន់យកព្រម" ១ ថា "ស្ថិតស្ថេរ" ១ ។ ឯពាក្យថា "កាន់យកព្រម" គឺភិក្ខុអ្នកក្រាល ឬភិក្ខុអ្នកអនុមោទនាអាចកាន់យកនូវអានិសង្ស ៥ មិនឲ្យត្រេចហួសទៅខេត្តដទៃបាន; ពាក្យថា "ស្ថិតស្ថេរ" គឺភិក្ខុអ្នកក្រាលទឹងភិក្ខុអ្នកអនុមោទនាកឋិនអាចធ្វើនូវអានិសង្ស ៥ ឲ្យមានទីបំផុតត្រឹមពេញបូណ៌មីខែផល្គុន ឬថាតាំងនៅក្នុងខាងក្នុងនៃកឋិនក្ខេត្ត ។ អធិប្បាយថាបើភិក្ខុបានក្រាលគ្រង់ឬអនុមោទនាកឋិនតាំងពីថ្ងៃ ១ រោចខែអស្សុជទៅ អានិសង្សកឋិនមាន ៥ ខែ, បើបានក្រាលឬអនុមោទនាកឋិន តាំងពីថ្ងៃពេញបូណ៌មីខែកត្តិកទៅ នោះ

អានិសង្សទាំង ៥ តាំងស្ថិតស្ថេរនៅអស់កំណត់ហោមន្តរជូវត្រឹមតែ ៤ ខែ; បពិត្រព្រះមហាថេរដ៏ចំរើន! ខ្ញុំព្រះករុណាបាទប្រែកឋិន សព្វព្រមទាំងសេចក្ដីអធិប្បាយបានសេចក្ដីប៉ុណ្ណេះ សូមជ្រាប ។

៣.— សាធុ សាធុ លោកម្ចាស់វិសជ្ជនាមកនេះ ខ្ញុំស្ដាប់បានចូលចិត្តហើយ ខ្ញុំនឹងសួរតទៅទៀត ។ អើលោកម្ចាស់! កឋិននេះ មានពីត្រឹមណាមក? មានដំណើររឿងរ៉ាវដូចម្ដេច បានជាព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យមានកឋិននេះឡើង? សូមលោកម្ចាស់និមន្តសំដែងឲ្យពិរោះក្បោះក្បាយមកមើល ។

— ភន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! ការសំដែងឲ្យពិរោះក្បោះក្បាយនោះពុំអាចអះអាងបានទេ ឯរឿងកឋិននេះមាននិទានជាវិត្ថារពិស្ដារ សូមសំដែងតាមសមត្ថភាពនៃការចេះដឹង ចំពោះកឋិនដែលមាននៅក្នុងកឋិនក្ខន្ធកៈ ដែលព្រះសង្គីតិកាចារ្យទាំងឡាយមានព្រះមហាកស្សបត្ថេរ ជាប្រធាន លោកសង្គាយនាតាំងទុកមកថា:—

សម័យមួយ សម្ដេចព្រះភគវន្តបពិត្រ ស្ដេចស្ថិតគង់សំរានក្សាន្តព្រះឥរិយាបថអភិរម្យដោយព្រហ្មវិហារប្រាកដនៅក្នុងព្រះមហាវិហារព្រះជេតពនសួគន្ធកុដី ជាអារាមនៃអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ពុំឆ្ងាយអំពីនគរសាវត្ថីជាបុរីសីមា គ្រាកាលនោះ មានភិក្ខុទាំងឡាយប្រមាណ ៣០ អង្គ មានប្រក្រតីគង់នៅក្នុងនគរបាវា បបួលគ្នាត្រេចតោចរទៅ

កាន់នគរសាវត្ថី ប្រយោជន៍ដើម្បីនឹងចូលទៅគាល់ព្រះបរមសាស្ដាចារ្យ វេលានោះជាវស្សូបនាយិកាសម័យ ជូនព្រះសង្ឃនឹងចូលព្រះវស្សាហើយ ឯភិក្ខុទាំង ៣០ រូបនោះ មានដំណើរមកក្នុងមគ្គាដ៏ឆ្ងាយ នឹងស្រូតទៅឲ្យដល់នគរសាវត្ថីពុំទាន់ ក៏ល្មមដល់ថ្ងៃចូលវស្សា ទើបនាំគ្នាចូលទៅអាស្រ័យចាំវស្សាទៅក្នុងក្រុងសាកេត ជាខេត្តទៀងនគរសាវត្ថី អស់ចំនួនខែ ៣ តាមសម័យត្រៃមាសជាកំណត់ លុះដល់ចេញវស្សាបវារណាហើយ ភិក្ខុទាំង ៣០ រូបនោះ ក៏បបួលគ្នាលាចេញអំពីក្រុងសាកេតបុរីធ្វើដំណើរទៅកាន់នគរសាវត្ថីរាជស្ថានពុំទាន់បានដល់ ដោយផ្លូវឆ្ងាយសែនលំបាកក្រៃ ព្រោះសម័យនោះក៏ជាវស្សានរដូវ ផ្លូវនោះប្រកបដោយទូវទឹកភ្លៀងផងភក់រជាប់ ឯចីពរស្បង់ សង្ឃាដីនៃភិក្ខុទាំងនោះ ក៏ជិតប្រឡាក់ទទឹកជោកដោយទឹកភ្លៀងតែរៀងៗ ពាល់ដំបន់ពាល់កខ្វង, ឯសរីរៈកាយនៃភិក្ខុទាំងនោះឯង ក៏និត្យនឿយទ្រុឌទ្រោម លុះល្មមដល់នគរសាវត្ថី ទើបនាំគ្នាចូលទៅគាល់សម្ដេចព្រះជិនស្រីក្នុងព្រះជេតពនមហាវិហារ ។ ឯព្រះដ៏មានព្រះភាគជាអគ្គបុគ្គល ស្ដេចទ្រង់យល់ភិក្ខុទាំង ៣០ រូបនោះ ដែលមានត្រៃចីវរសៅហ្មងដោយទូវទឹកភ្លៀងទទឹកជ្រោះហើយ ទើបទ្រង់ត្រាស់បដិសណ្ឋារៈ សួរទទួលដោយពុទ្ធដីកាតាមធម្មតាហើយទ្រង់ព្រះមហាករុណាក្នុងវេនេយ្យពុទ្ធបរិស័ទ អាស្រ័យហេតុនោះជាទិទាន ទើបមានពុទ្ធដីកាត្រាស់ហៅភិក្ខុទាំងឡាយ មកប្រជុំសន្និបាត

ហើយទ្រង់អនុញ្ញាតកឋិនត្ថារវិនយកម្មថា "អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ" "ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតឲ្យពួកភិក្ខុដែលបាននៅចាំវស្សារួចហើយក្រាលកឋិនបាន" ។ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ចានិសំសានិ កប្បិស្សន្តិ "ម្នាល-ភិក្ខុទាំងឡាយ! កាលបើអ្នកទាំងឡាយបានក្រាលកឋិនហើយ នឹងបានសម្រេចអានិសង្ស ៥ ប្រការដោយពិត" ។ បពិត្រព្រះមហាថេរ! ឯដំណើរដើមដែលនាំឲ្យកើតកឋិនក្នុងសាសនា ដូចន័យដែលបានវិសជ្ជនាមកនេះ សូមទានជ្រាប ។

៤.- សាធុ សាធុ ម្នាលអនុគ្គេរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកពិរោះក្បោះក្បាយហើយ, ខ្ញុំសូមសួរតទៅទៀត ។ លោកម្ចាស់សំដែងថា "ភិក្ខុដែលបានក្រាលគ្រងកឋិន នឹងភិក្ខុដែលបានទទួលអនុមោទនានូវកឋិននោះ ថានឹងបានសម្រេចអានិសង្ស ៥ ប្រការ" ចុះអានិសង្ស ៥ ប្រការនោះតើគឺអ្វីខ្លះ? សូមរៀបរាប់មកទៀតមើល ។

— បពិត្រព្រះមហាថេរ! ឯអានិសង្ស ៥ ប្រការ ដែលសម្រេចអំពីកឋិនទានដល់ពួកភិក្ខុនោះគឺ:

ក)— អនាមន្តចារោ ភិក្ខុណាពុំបានលាពុំបានប្រាប់ភិក្ខុជាសព្រហ្មចារ្យ នៅក្នុងអារាមជាមួយគ្នា ហើយត្រាច់ទៅកាន់ត្រកូលក្នុងវេលាព្រឹកឬវេលាល្ងាច, ភិក្ខុនោះត្រូវអាបត្តិដោយចារិត្តសិក្ខាបទ; ថា

បើភិក្ខុនោះបានគ្រងកឋិនក្តី អនុមោទនាកឋិនក្តី ទោះបីមិនបានប្រាប់មិនបានលាភិក្ខុជាសព្រហ្មចារីនៅជាមួយគ្នា ហើយទៅកាន់ត្រកូល ក៏ឥតត្រូវអាបត្តិ ព្រោះអានិសង្សនៃកឋិន អាចការពារអាបត្តិដល់ភិក្ខុនោះឯង ។

ខ)– អសមាទានចារោ. ភិក្ខុណាលះត្រៃចីវរឯណាមួយដែលជាទីរក្សាក្នុងកាលអរុណរះឡើងទុកហើយចេញចាកទីលំនៅ ឲ្យកន្លងអរុណមាត្រាតែពេត្រី ១ នឹងត្រូវអាបត្តិដោយចីវរវិប្បវាសសិក្ខាបទ; បើភិក្ខុនោះបានក្រាលគ្រងអនុមោទនាកឋិន ទោះបីលះត្រៃចីវរទុកឲ្យកន្លងរាត្រី ក៏ឥតត្រូវអាបត្តិ ព្រោះអានិសង្សនៃកឋិននោះឯង ។

គ)– គណភោជនំ ភិក្ខុទទួលចង្ហាន់គណភោជនតាំងតែអំពី ៤ រូបឡើងទៅ ហើយមានទាយកមកនិមន្តដោយពោលហារគ្រហស្ថ មិនសមគួរដល់សមណកប្បជាដើមថា "និមន្តលោកឆាន់បាយ ឆាន់សម្ល ឆាន់ត្រីឆាន់សាច់ជ្រូកជាដើម" ទៅឆាន់ក៏ត្រូវអាបត្តិដោយគណភោជនសិក្ខាបទ; បើភិក្ខុតាំងពី ៤ អង្គឡើងទៅ បានក្រាល បានអនុមោទនាកឋិនហើយ ទោះបីទៅឆាន់ភោជននៃទាយកនោះក៏ឥតត្រូវអាបត្តិ ។

ឃ)– យាវទត្ថចីវរំ ភិក្ខុបានចីវរលាភតាំងពីមក ហើយពុំបានអធិដ្ឋានវិកប្បហើយ ទុកឲ្យកន្លងរាត្រី ១០ ថ្ងៃទៅដូច្នេះក៏ពុំត្រូវអាបត្តិឡើយ ។

ង)– យោ ប តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ

ចីវរដែលកើតអំពីទាយកថ្វាយចំពោះជាសង្ឃទានក្តី ចីវរកើតអំពីធរណីសង្ឃ គឺថ្លៃស្រែចំការវត្តក្តី មតកចីវរ គឺចីវររបស់ភិក្ខុសាមណេរដែលដល់អនិច្ចធម្មក្តី សង្ឃិកចីវរទាំង ៣ ប្រការ ដែលកើតក្នុងដែនគឋិនាវាសក៏បានដល់ភិក្ខុដែលបានក្រាលអនុមោទនាកឋិនពួកមួយនោះឯង តែភិក្ខុដាច់វស្សាក្តី ភិក្ខុដែលចូលបច្ឆិមវស្សាគឺចូលក្នុងថ្ងៃ ១ កើតខែស្រាពណ៍នោះក្តី មិនត្រូវបានចំណែកចីវរនោះផងឡើយ ។

បពិត្រព្រះមហាថេរ! ឯកឋិនទានមានអានិសង្សអាចការពារអាបត្តិ ៥ ប្រការ ដូចសំដែងមកនេះ ចំពោះមានកាលកំណត់ តាំងអំពីថ្ងៃដែលបានក្រាល - អនុមោទនាកឋិនមក ដរាបដល់ថ្ងៃបូណ៌មីខែផល្គុន ជាថ្ងៃបំផុតដោះកឋិនដោយប្រការដូច្នេះឯង សូមទានជ្រាប ។

(មានត)

កឋិនទាន មានក្នុង ពុទ្ធសាស្នា, ព្រះត្រាស់ថា បានផល ពីរចំណែក:
អ្នកដែលឲ្យ បានបុណ្យ អតិរេក តាមលោកថែក មានប្រាំ ប្រការណា ។
គឺអាយុ វណ្ណៈ នឹង សុខៈ ពលៈ បដិភាណ តាមតំរា
អ្នកទទួល តែងបាន អានិសង្សា ប្រាំប្រការ ការពារ អាបត្តិបាន ។

# សេចក្ដីល្អ-សេចក្ដីអាក្រក់

## លោក ស៊ុន-ហាន ស្មៀននៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

អស់លោក-អ្នកសប្បុរសទាំងឡាយ ! អំពើកាយ មានសុភាពរាបសារ មានសណ្ដាប់ធ្នាប់ល្អ មិនឃ្លើសឃ្លងប្រឡេងខាម មិនលួចប្លន់ មិនកាប់សម្លាប់បំបាត់ជីវិតសត្វនិងបុគ្គលដទៃ ជាដើម ឈ្មោះថា ការល្អផ្លូវកាយ; អំពើកាយមានសភាពផ្ទុយអំពីនេះ ឈ្មោះថាការអាក្រក់ផ្លូវកាយ; ការពោលពាក្យទន់ភ្លន់ផ្អែមល្ហែមពីរោះជាទីគាប់ចិត្ត ជាពាក្យមានប្រយោជន៍ដល់អ្នកស្ដាប់ ជាពាក្យពិតមិនភូតភរកុហក មិនញុះញង់ចាក់រុក មិនឆ្កេះឆ្កៀលរករឿង មិនបង្កហេតុឈ្លោះប្រកែក ជាដើម ឈ្មោះថាការល្អផ្លូវសំដី; ការពោលវាចាខុសទំនងអំពីនេះ ឈ្មោះថាការអាក្រក់ផ្លូវសំដី; ចិត្តស្លូតបូតមិនព្រហើនកោងកាច មានមេត្តាករុណាត្រាប្រណីអ្នកដទៃ ស្មោះត្រង់មិនវៀចវេរ ជាដើម ឈ្មោះថាការល្អផ្លូវចិត្ត; ចិត្តព្រហើនកោងកាច គ្មានមេត្តាករុណាមិនស្មោះត្រង់ជាដើម ឈ្មោះថាការអាក្រក់ផ្លូវចិត្ត ។

សត្វលោកតែងស្អប់ខ្ពើមនូវសេចក្ដីអាក្រក់ ត្រូវការប្រាថ្នាចង់បានតែសេចក្ដីល្អ តែសេចក្ដីអាក្រក់នឹងសេចក្ដីល្អ ដែលនឹងកើតមានឡើង

បានក៏ត្រូវមានការធ្វើជាហេតុ ។ ហេតុនោះ ការធ្វើទើបជារបស់សំខាន់បំផុតក្នុងរឿងល្អនិងអាក្រក់ មិនគួរមើលងាយការធ្វើថាមានប្រមាណតិចតួចទេ ព្រោះការធ្វើបន្តិចបន្តួចញយដងនោះឯង ជាហេតុឲ្យច្រើនបាន ។ អស់លោក-អ្នកសប្បុរសទាំងឡាយ ! យើងគួរតក់ស្លុតចិត្តចំពោះការធ្វើប្រការខ្លះ ដែលប្រព្រឹត្តទៅក្នុងផ្លូវមិនល្អ ដឹងហើយហ៊ានធ្វើទាំងបំពានគិតទៅមិនគួរនឹងធ្វើបានសោះ តែត្រឡប់ជាធ្វើបានទៅវិញ, កិរិយាដែលពោលមកនេះ មាននៅពាសពេញក្នុងលោក ។ សូម្បីការធ្វើខ្លះ ដូចសេចក្ដីក្រោធជាដើម ម្ចាស់ខ្លួនដឹងហើយថាជារបស់មិនល្អ ដូចជាក្នុងក្នុងពេលខ្លះក៏ព្រមឲ្យនៅក្រោមអំណាចសេចក្ដីក្រោធ បណ្ដោយឲ្យសេចក្ដីក្រោធញាំញីចិត្តបាន ។ កិរិយាធ្វើបែបនេះអ្នកប្រាជ្ញមានព្រះសម្ពុទ្ធជាដើមមិនទ្រង់សរសើរឡើយ ។

បើមានមនុស្សដទៃមកសំដែងសេចក្ដីក្រេវក្រោធជាដើម ដាក់ខ្លួនយើង ៗ គង់មិនពេញចិត្ត តែបើខ្លួនយើងធ្វើដល់មនុស្សដទៃវិញ ក៏បេះតែធ្វើទៅបានឥតមានកោតក្រែងចិត្តគេឡើយ ។ មនុស្សដែលធ្វើដូច្នេះក៏ព្រោះឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ទោសរបស់ខ្លួនឯងមិនឃើញទៅឃើញតែទោសមនុស្សដទៃវិញ ។ ការដឹងផ្សេង ៗ ដែលបានមកអំពីការឃើញ, ការស្ដាប់, ការស្រូបក្លិន, លិទ្ធរស, សម្ផស្ស, ការនឹកគិតនឹងការធ្វើនោះ ត្រូវសេចក្ដីឃើញចំពោះខ្លួនជាទីបាំងអស់ ប្រើការ

ជាប្រយោជន៍មិនបាន ៗ អស់លោកសប្បុរសទាំងឡាយ! សូមកុំភ្លេចថា វិជ្ជាដែលបានរៀនមក ដើម្បីជាគ្រឿងប្រតិបត្តិឲ្យបានសម្រេចប្រយោជន៍ សេចក្ដីល្អឲ្យផុតអំពីសេចក្ដីអាក្រក់ មួយទៀត គប្បីយល់ថា ការបៀតបៀន, ការមើលងាយ, សេចក្ដីអយុត្តិធម៌, ការកំហែង, ការយកប្រៀបនិងរឿងដែលអាក្រក់ជាដើម ខ្លួនយើងមិនប្រាថ្នាគ្រប់ៗគ្នា សុទ្ធតែដឹងជាក់ច្បាស់ថា ជាអំពើមិនល្អហើយ តែទោះបីដូច្នោះក៏គង់មានគេហ៊ានប្រព្រឹត្តធ្វើទៅបាន ៗ ហេតុនោះផ្លូវច្បាប់សម្រាប់ស្រុកទេស និងផ្លូវវិន័យរបស់ពុទ្ធសាសនា ទើបមានខហាមប្រាមចំពោះការធ្វើអាក្រក់ ៗ ការឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ជាហេតុមិនឲ្យមានយុត្តិធម៌នៅក្នុងខ្លួន ៗ អស់លោក-អ្នកសប្បុរសទាំងឡាយ ត្រូវនាំគ្នាប្រយ័ត្នឲ្យណាស់ ចំពោះអំពើអយុត្តិធម៌នេះ ៗ ព្រោះជារបស់កាច, បើពួកមនុស្សប្រយ័ត្នបានហើយ ពួកសត្វក៏រស់នៅជាសុខ និងមិនក្ដៅក្រហាយ ព្រោះកម្លាំងដៃរបស់មនុស្សឡើយ ៗ

ដែលពិតត្រូវតែធ្វើខ្លួនឲ្យជាអ្នកល្អ សូម្បីខ្លួនមិនមានការចេះដឹងច្រើន ក៏អាចនឹងធ្វើបានដោយកំណត់ចិត្តរបស់ខ្លួនឯង ហើយចាំសង្កេតមើលការធ្វើរបស់បុគ្គលដទៃ ដូចសេចក្ដីសុខសប្បាយ, ការមិនត្រូវកំហែង, លះកយស, ការមិនត្រូវបៀតបៀន, មានមេត្តាករុណា, និងរឿងពិរោះទន់ផ្អែមជាដើម ទាំងនេះយើងពេញចិត្តណាស់, កាលយើងពេញ

ចិត្តហើយអ្នកដទៃក៏ពេញចិត្តដែរ ។ គេធ្វើយ៉ាងនេះដល់យើងៗ មិនពេញចិត្ត ក៏គួរចាំទុកព្រមទាំងតាំងចិត្តថា យើងនឹងមិនធ្វើកិរិយាដូច្នេះដល់អ្នកណា ៗ ឡើយ ។ គេធ្វើយ៉ាងនេះដល់យើងៗពេញចិត្ត ក៏គួរចាំទុកព្រមទាំងតាំងចិត្តថា យើងនឹងរកឱកាសធ្វើដូច្នេះដល់គេឲ្យបាន ។ កិរិយាធ្វើដូច្នេះ អ្នកប្រាជ្ញហៅថា ចេតោបរិយញ្ញាណ មាននៅក្នុងសន្តានអ្នកណា អ្នកនោះចាត់ថាជាមនុស្សជាន់ខ្ពស់ ជាអ្នកល្អដែលរកបានដោយកម្រ, សេចក្ដីអាក្រក់សូម្បីបន្តិចបន្តួចក៏មិនចង់ឲ្យមាននៅក្នុងសន្តានឡើយ ។ ហេតុនេះ អស់លោកសប្បុរសទាំងឡាយ គួរប្រយ័ត្នចំពោះការធ្វើឲ្យមែនទែន កុំបណ្ដោយឲ្យខូចសេចក្ដីតាំងចិត្តដែលមានក្នុងសន្តានថា ចង់ឲ្យខ្លួនបានជាអ្នកល្អ, ជាអ្នកមានតម្លៃ, ចិត្តមាននាទីសម្រាប់គិតនឹកក៏គួរគិតឲ្យហ្មត់ចត់ជាមុន ហើយទើបធ្វើការ, យើងមាននាទីធ្វើសេចក្ដីល្អជាក់ខ្លួន ក៏គួរលះអាក្រក់ប្រព្រឹត្តល្អ ។ មនុស្សដែលធ្វើសេចក្ដីក្ដៅក្រហាយឲ្យដល់សត្វលោក, លោកហៅថា "មនុស្សចង្រៃតលោក" មនុស្សដែលធ្វើគុណសេចក្ដីល្អឲ្យដល់សត្វលោកចំរើនរុងរឿងលោកហៅថា "អ្នកញ៉ាំងលោកឲ្យក្ដីស្មាន" ខ្លួនរបស់ខ្លួនឯង ជារបស់រកបានដោយកម្រ មានតម្លៃច្រើន កុំឲ្យតម្លៃនឹងគុណសេចក្ដីល្អ របស់ខ្លួននោះអាប់ឱនថាបថោកទៅ ព្រោះការធ្វើរបស់ខ្លួនឯងឡើយ ព្រោះជាការគួរខ្មាសណាស់ ។

អ្នកដែលមិនបានសំឡឹងពិនិត្យខ្លួនឯង ត្រឡប់ទៅសំឡឹងពិនិត្យកង្វះដទៃវិញ ឈ្មោះថា មិនឃើញសេចក្តីខុសរបស់ខ្លួនទេ សេចក្តីខុសគ្រប់យ៉ាងធ្លាក់ដល់មនុស្សដទៃ ខ្លួនរបស់ខ្លួនឯងនេះតែល្អទាំងអស់ ៗ បើធ្វើបំពានដូច្នេះ លោកនេះ នឹងទៅជាលោកដែលល្វឹងល្វើយបត់ ហើរទារទីបំផុតរកសេចក្តីសុខបានដោយកម្រ ដែលមិនត្រង់នឹងសេចក្តីប្រាថ្នារបស់សត្វលោកឡើយ ៗ សេចក្តីល្អ, ហេតុនៃសេចក្តីចំរើន, ហេតុនៃសេចក្តីសុខ ដែលរួមហៅថា ធម៌ ព្រះពុទ្ធអង្គទ្រង់ស្វែងរកដោយព្រះអង្គឯង ទ្រង់លះដោយព្រះអង្គឯង ទ្រង់ប្រព្រឹត្តដោយព្រះអង្គឯង ទ្រង់ល្បងមើលដោយព្រះអង្គឯង អស់វេលា ៦ ឆ្នាំ ស្ទើរតែនឹងអស់ព្រះជន្មទៅហើយ ដែលរាប់ថាជាការកម្រទីបំផុត ៗ យើងកើតមកខាងក្រោយមិនបាច់ស្រាវជ្រាវរកព្រះធម៌ទេ ព្រះអង្គទ្រង់ត្រាស់ប្រាប់ទុកជាស្រេចដូចបរិភោគបាយដែលគេដួសដោះទុកហើយ គួរតែយើងទាំងអស់គ្នាធ្វើតាមព្រះអង្គ នឹងធ្វើតាមមិនបានឬ? គិតមើលឲ្យគ្រប់គ្រាន់ល្អ បើយើងធ្វើតាមមិនបានហើយ ក៏គួរឲ្យខ្មាសណាស់ ៗ ខ្លួនរបស់ខ្លួនឯង បាត់ពត់បានដោយកម្រ ត្រូវអាស្រ័យសេចក្តីព្យាយាមធ្វើដោយមិនលះធុរៈទើបនឹងតស៊ូបាន, និស្ស័យរបស់មនុស្សដែលចង់ឈ្នះជានិច្ច ទើបគួររាប់ថាជានិស្ស័យដែលល្អ ៗ ហេតុនេះគប្បីឈ្នះខ្លួនឯងចុះ លោកពោលទុកថា អ្នកឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់ពាន់ដងក៏មិនប្រសើរ

ស្មើមនុស្សដែលឈ្នះខ្លួនឯងមុន ៗ គប្បីគិតពិនិត្យខ្លួនឯង គយគន់មើលខ្លួនឯង ឲ្យឃើញទោសរបស់ខ្លួនឯង កាលឃើញហើយត្រូវលះរបស់ដែលគួរលះ បំពេញរបស់ដែលខ្វះខាតឲ្យបរិបូណ៌ លុះពិចារណាតទៅទៀតឃើញថាមិនមានទោសហើយគប្បីកាន់យកធម៌ គឺសេចក្ដីល្អ សេចក្ដីអាក្រក់នេះ ជាអនុស្សរណន័យប្រចាំចិត្តគ្រប់ពេលវេលា ៗ

ដើម្បីជាគ្រឿងជាស់តឿនចិត្ត មិនឲ្យធ្វើសេចក្ដីអាក្រក់បាន. តអំពីនោះនឹងឃើញខ្លួនឯងជាមនុស្សល្អម្នាក់គង់ថ្ងៃខាងមុខ តែត្រូវប្រយ័ត្នការឃើញចំពោះខ្លួនឯង ៗ ការកំចាត់បង់នូវសេចក្ដីឃើញចំពោះខ្លួនឯងជាមុន ទើបយកសេចក្ដីយុត្តិធម៌មកជំនួសបាន ធ្វើខ្លួនរបស់ខ្លួនយើងឲ្យស្មើនឹងសត្វលោក ហើយប្រព្រឹត្តឲ្យស្មោះស្មើដែលហៅថាយុត្តិធម៌ ឲ្យសមគួរដល់ឋានៈរបស់ខ្លួន ៗ ក៏នឹងបានចំរើនពិតប្រាកដ ៗ

សេចក្ដីល្អជារបស់យើង សេចក្ដីអាក្រក់ក៏ជារបស់យើង
គេក៏មានចិត្តយើងក៏មានចិត្ត ធ្វើអ្វីត្រូវគិតមុខក្រោយ ៗ

ស៊ុន - ហ៊ាន

## ការបណ្ដុះជំស្រួយ

ព្រះមហាឧត្ដមវិជ្ជា ផលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

ប៉ុន្តែ មនុស្សដែលមិនត្រិះរិះក្នុងផ្លូវសាសនា ច្រើនតែឃើញថា សាសនាជាពាក្យប្រៀនប្រដៅ ដែលសាស្ដាចារ្យបញ្ញត្តឡើងក្នុងយុគនៃមនុស្សល្ងង់ខ្លៅ សម្រាប់បោកប្ញុំគំរាមមនុស្សជំនាន់នោះៗ ឲ្យធ្វើតាមបំណង លុះដល់មកខាងក្រោយក្លាយទៅជាវត្ថុសង្កត់សង្កិនចំពោះការប្រព្រឹត្តទៅដោយសេរីរបស់មនុស្សទាំងឡាយវិញ ។ តាមការពិត មិនដែលមានប្រទេសឯករាជ្យឬមហាអំណាចណាមួយ ដែលគ្មានអំណាចខាងច្បាប់ទំលាប់ជាធំខ្ពង់ខ្ពស់បំផុតឡើយ ។ តែសូម្បីមានអំណាចច្បាប់ទំលាប់ជាធំដូច្នោះក៏ដោយ ច្បាប់ទំលាប់ក៏នៅតែគ្រប់គ្រងការពារគ្នាមិនបានជិតស្និទ្ធប្រហែលនឹងសាសនាដែរ ។ ព្រោះអំណាចច្បាប់ទំលាប់ ការពារមនុស្សមិនឲ្យប្រព្រឹត្តខុសបានតែត្រឹមផ្លូវកាយនឹងវាចា ។ ចំណែកសាសនា អាចរក្សាមនុស្សមិនឲ្យប្រព្រឹត្តខុសបានគ្រប់ទាំងត្រៃទ្វារ ។ បើជាតិណាគ្មានសាសនាឃុំគ្រងទេ មនុស្សក្នុងជាតិនោះ ក៏នឹងគ្មានគោលចារឹកក្នុងផ្លូវប្រតិបត្តិ អាចប្រព្រឹត្តអាក្រក់ខុសធម៌ទៅតាមទំនើងចិត្តរបស់

ខ្លួនដែលជាហេតុចង្អុលឲ្យឃើញថា ទៅក្នុងអនាគត ដោយសារតែសេចក្តីប្រព្រឹត្តអាក្រក់របស់មនុស្សក្នុងជាតិនោះឯង ជាតិក៏មុខជានឹងដល់នូវសេចក្តីវិនាសលិចលង់មិនខាន មិនអាចតាំងនៅជាជាតិ មានឥស្សរភាពបានឡើយ ។

ព្រះពុទ្ធសាសនា ជាសាសនាប្រចាំជាតិខ្មែរ ។ ព្រះធម៌វិន័យដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហៅថា ព្រះពុទ្ធសាសនា ។ ព្រះធម៌ដែលព្រះអង្គទ្រង់សំដែងទូន្មាន ជាគោលនៃសេចក្តីពិត ឬជាវត្ថុដែលរក្សាទុកនូវសេចក្តីពិត ជាអណ្តូងកើតនៃសន្តិសុខ សូម្បីមានបែកខ្នែងទៅជាច្រើនយ៉ាងក៏ដោយ បំណុចទីបំផុតក៏ទៅរួមនៅក្នុងសេចក្តីពិតដែលចាត់ថាជាវត្ថុធម៌ដ៏ប្រសើរបំផុត អាចនាំលោកឲ្យល្អបានគ្រប់ករណីគ្រប់ឋានៈ ។ ព្រះវិន័យជាច្បាប់បង្គាប់ដែលព្រះអង្គទ្រង់បញ្ញត្តទុកដើម្បីឃុំគ្រងពួកគណៈ មានអំណាចគឺអាជ្ញាខាងការដាក់ទោសដល់អ្នកប្រព្រឹត្តល្មើស នឹងធ្វើឲ្យមានរបៀបរៀបរយ នាំឲ្យអ្នកធ្វើខុស បានត្រឡប់ទៅជាធ្វើត្រូវ ទោះបីសេចក្តីខុសនោះមានចេតនាឬមិនមានក៏ដោយឲ្យតែជាការមិនត្រឹមត្រូវតាមព្រះវិន័យ ។

ព្រះពុទ្ធសាសនា គឺព្រះធម៌វិន័យនេះប្រសើរបំផុត អាចធ្វើអ្នកដែលស្រឡាញ់ក្តីគោរពប្រតិបត្តិតាម ឲ្យបានសេចក្តីបរិសុទ្ធផុតចាកទោស ឲ្យបរិបូណ៌ដោយគុណវុឌ្ឍិ ឲ្យជាមនុស្សល្អ ជាមនុស្សចំរើន

ឲ្យផុតចាកភាពជាមនុស្សអាក្រក់មនុស្សវិនាស និង ឲ្យមានសុខផុតចាកទុក្ខបានតាមជាន់តាមសមគួរដល់សេចក្ដីប្រតិបត្តិរៀងពល់ខ្លួន ៗ ព្រោះជាព្រះពុទ្ធសាសនា មានសារៈសំខាន់ នៅត្រង់សេចក្ដីល្អ សេចក្ដីពិត និងសេចក្ដីបរិសុទ្ធយ៉ាងខ្ពស់បំផុត ។ លោកអ្នកដែលកាន់អានព្រះពុទ្ធសាសនាទាំងឡាយ ! លោក-អ្នកមានសេចក្ដីស្រឡាញ់កក្ដីចំពោះព្រះពុទ្ធសាសនាមែនដែនហើយឬនៅ ? សូមពិចារណាមើលចំពោះខ្លួនលោកអ្នកផងចុះ ៗ បើលោក-អ្នកមានសេចក្ដីស្រឡាញ់កក្ដីពិតហើយ លោកអ្នកមុខជានឹងឃើញអង្គនៃសេចក្ដីស្រឡាញ់កក្ដីនោះ ច្បាស់ប្រាកដនៅក្នុងខ្លួនរបស់លោក-អ្នកមិនខានឡើយ ៗ ឯអង្គនៃសេចក្ដីស្រឡាញ់កក្ដីចំពោះព្រះពុទ្ធសាសនានោះដូច្នេះ គឺ :

ក) - មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយ៉ាងមាំមួន យកព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាសរណៈទីពឹងទីរឭករហូតដល់អស់ជីវិត មិនកាន់អានសរណៈវត្ថុដទៃឲ្យលើសលប់ជាង ៗ

ខ) - តាំងចិត្តសិក្សាព្រះពុទ្ធសាសនា ឲ្យកើតមានបញ្ញាឲ្យចូលចិត្តជាក់លាក់ ឲ្យស្គាល់ខុសត្រូវអាក្រក់ល្អល្មមនឹងកាន់យកជាគោលនៃការប្រព្រឹត្តរបស់ខ្លួនបាន ៗ

គ) - ប្រតិបត្តិតាមព្រះពុទ្ធសាសនាដោយគោរព គឺតាំងចិត្តលះអាក្រក់ប្រព្រឹត្តល្អ និងធ្វើចិត្តឲ្យបរិសុទ្ធថ្លាផូរផង់ តាមព្រះវិន័យរបស់ព្រះពុទ្ធ ៗ

ឃ)- ណែនាំអ្នកដែលមិនទាន់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ឲ្យកើតសទ្ធាជ្រះថ្លានឹងប្រតិបត្តិតាម ដឹកនាំអ្នកដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាខ្លាំងឡើង នឹងឲ្យរឹងរឹតតែប្រតិបត្តិតាមយ៉ាងតឹងរឹងទៅទៀត

ង)- ទំនុកបំរុងកិច្ចការរបស់ព្រះពុទ្ធសាសនា ទាំងខាងផ្លូវសិក្សា ទាំងខាងផ្លូវប្រតិបត្តិ រហូតដល់កិច្ចការដទៃដែលជាគ្រឿងលើកដំកើងព្រះពុទ្ធសាសនាឲ្យវ័យវឌ្ឍនាការជាស្ថាពរ ដោយកម្លាំងទ្រព្យ កម្លាំងកាយ នឹងកម្លាំងជម្រែះប្រាជ្ញារបស់ខ្លួន ។

ច)- រក្សាព្រះពុទ្ធសាសនាឲ្យបរិសុទ្ធបរិបូណ៌គង់វង់នៅ មិនផ្លាស់ប្តូរកែខែឲ្យខុសខូចទៅតាមចិត្តគំនិតរបស់ខ្លួន ព្យាយាមលើកខ្លួនឡើងទៅរកព្រះពុទ្ធសាសនា មិនទាញព្រះពុទ្ធសាសនាឲ្យចុះមករកខ្លួនវិញឡើយ ។

ឆ)- ការពារមិនឲ្យកើតមានសេចក្តីវិនាសដល់ព្រះពុទ្ធសាសនា គឺកាត់ផ្តាច់ដើមហេតុ នឹង រំងាប់កិច្ចការដែលបណ្តាលឲ្យព្រះពុទ្ធសាសនាថោកទាបសៅហ្មងចោលចេញ ។

លោក-អ្នកពុទ្ធសាសនិកជនទាំងឡាយ ! កាលបើលោក-អ្នកប្រាថ្នានឹងកសាងព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿងហើយ ចូរលះបង់សេចក្តីសុខផ្ទាល់ខ្លួនចេញហើយ ខំតាំងព្យាយាមប្រតិបត្តិតាមអង្គនៃសេចក្តីស្រឡាញ់កក្តីដូចថ្លែងមកនេះ ដោយតាំងចិត្តសិក្សានឹងប្រតិបត្តិអប់រំខ្លួនឲ្យ

ល្អត្រឹមត្រូវឡើងជាដាច់ៗ យ៉ាងហោចណាស់ក៏ឲ្យមានមារយាទល្អ ឬឲ្យមានសីលធម៌សម្រាប់ប្រដុំដុន ឲ្យសមនឹងភាពជាមនុស្សក្នុងលោកនេះ ប៉ុយ៉ាងកណ្ដាលក៏ឲ្យល្អប្រពៃ សម្រាប់ជាផ្លូវសុគតិក្នុងភពមុខ បើយ៉ាងខ្ពស់ គឺជំរះចិត្តរបស់ខ្លួនឲ្យបរិសុទ្ធដល់នៅសេចក្ដីរលត់ទុក្ខ ឬផុតចាកកិលេសដោយអស់ជើង ឬកាលបើសិក្សាចេះដឹងហើយ ប្ដូរធ្វើចំណេះនោះឲ្យកើតផលគឺការប្រតិបត្តិ ធ្វើការប្រតិបត្តិឲ្យកើតផលគឺការផ្លាប់ថ្នឹក ធ្វើទំលាប់ថ្នឹកឲ្យកើតផលគឺឧបនិស្ស័យ នឹងធ្វើឧបនិស្ស័យឲ្យកើតផលគឺភាពជាមនុស្សល្អក្នុងត្រកពរហូតដល់ឋានៈជាមនុស្សលែងទាក់ទាម នឹងសេចក្ដីល្អធំផុតអំពីត្រកពឡើងទៅតាំងនៅលើទីបំផុតលោក (និព្វាន)ៗ សូម្បីកាលដល់គ្រាត្រូវការ ក្នុងពេលដែលព្រះពុទ្ធសាសនាត្រូវថោកទាប ព្រោះមានភ័យមកញាំញីធ្វើឲ្យសាបសូន្យ ក៏ប្ដូរលោក អ្នកលះបង់ប្រយោជន៍ផ្ទាល់ខ្លួនគ្រប់យ៉ាង ដើម្បីជួយថែទាំរក្សាការពារព្រះពុទ្ធ-ឲ្យបានគង់វង់នឹងចំរើនរុងរឿងឡើងវិញ ៗ សូមនឹកដល់សុភាសិតក្នុងសាសនា អសីតិនិបាតជាតកថា "ដើម្បីនឹងរក្សាអវយវៈ មនុស្សយើងគប្បីលះបង់ទ្រព្យ, ដើម្បីនឹងរក្សាជីវិត គប្បីលះបង់អវយវៈ, តែកាលនឹកដល់ព្រះធម៌ គប្បីលះបង់ឲ្យអស់ទាំងទ្រព្យ ទាំងអវយវៈ ទាំងជីវិត" ៗ

ដើម្បីនឹង រក្សា អវយវៈ
ត្រូវហ៊ានស្ម័គ្រ លះបង់ សព្វធនធាន,

ដើម្បីថៃ ជីវិត ឲ្យរស់គន
ត្រូវចិត្តហ៊ាន លះបង់ អង្គកាយា ។
តែដើម្បី រក្សា ព្រះធម៌ថ្លៃ
នៃសម្ដេច បរមត្រៃ ព្រះសាស្តា
ត្រូវតែលះ ទាំងអស់ កុំសោកា
គឺកាយា ទ្រព្យធន និងជីវិត ។

៣.— ការស្រឡាញ់ភក្ដីបំពោះព្រះមហាក្សត្រ.— ព្រះមហាក្សត្រជាបមមកុដ ជាប្រមុខនៃប្រជាជនរបស់ជាតិ ជាទីប្រជុំចុះនៃអំណាចត្រូវតាមធម៌ (ច្បាប់) ដែលទុកថាជាកំពូលរបស់ជាតិ កងការរំងាប់ហេតុការណ៍ខុស-អាក្រក់ និង ការពារបច្ចាមិត្ត ។ ប្រមុខនោះប្រៀបដូចជាចំណែកដ៏ប្រសើរបំផុតរបស់កងកាយ គឺសិរសា ។ សិរសារមែងជាប្រធានរបស់កងកាយ ។ បើកងកាយដាច់សិរសាហើយនឹងរស់នៅយ៉ាងណាបាន ។ ព្រះមហាក្សត្រក៏ជាទីគោរពសក្ការបូជាយ៉ាងក្រៃលែងរបស់ប្រជាជន កងឋានៈជាប្រមុខ ប៉ុនគ្នានឹងសិរសារបស់មនុស្សដែរ បើខ្វះប្រមុខហើយ ប្រជាជនក៏ខ្វះអ្នកដែលជាទីពឹងដើម្បីការពារឲ្យបានសន្តិសុខ ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ១៦

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជការឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

តាំងពីចូឆូ ចាត់ប្រើហេហួទុនជាទ័ពស្រួច ចាត់ទ្បៀពីជាទ័ពស្តាំ លីប៉ោជាទ័ពឆ្វេង ចូឆូឯងជាទ័ពហ្លួងលើកទៅវាយស្រុឡាំយ៉ុង រហូតដល់លីប៉ោលើកទ័ពទៅវាយស្រុកសៀវផាយ ទ្បៀពីប្រើកាន់យ៉ុងទៅសុំកងទ័ពចូឆូមកជួយ ។

---

ឯចូឆូនោះ តាំងពីខូចទៀនអ៊ុយទៅពេលណា មិនដែលបានសេចក្តីសប្បាយរីករាយសោះ ឲ្យតែមានគិតស្តាយដល់ទៀនអ៊ុយពន់ប្រមាណ ចេះតែសែនគ្រឿងសក្ការៈឲ្យមិនដែលដាច់ ហើយឲ្យយកខ្លួនទៀនមួនជាបុត្រទៀនអ៊ុយមកតាំងជាតងឡ្យង គឺជំនិតជិតខ្លួន ទទួលមានសំបុត្រស៊ុនស៊ិកទៅដល់ ចូឆូក៏មើលដឹងក្នុងសេចក្តីសំបុត្រ ហើយមិនទាន់នឹងថាប្រការម្តេច មានទាហានចូលមកជំរាបថា ស្រុកឡាំយ៉ុងនោះស្រូវអង្ករ

ស្បៀងអាហារឥឡូវនេះក្រខ្សត់ណាស់ហើយ អ្នកស្រុកកំពុងប្រមូលសេនាទាហានទៅវាយដណ្តើមយកស្រុកតាន់លីវ ៗ ប៊ូចូបានឮដូច្នោះក៏គិតឃើញថា "ក្នុងស្រុកឡាំយ៉ុងនោះ ទាហានក៏កាន់តែស្តួចស្តើង បើយើងនឹងលើកទ័ពទៅវាយក៏នឹងបានដោយងាយ" ទើបឲ្យធ្វើសំបុត្រទៅដល់ឡេវពី ស៊ុនសិកនឹងលីប៉ោ ឲ្យលើកកងទ័ពទៅជួបគ្នាវាយយកស្រុកឡាំយ៉ុង, ហើយទុកហោយិនឲ្យនៅរក្សាស្រុកហ៊ូតោ ហើយប្រមូលពលទាហានបាន ៧០ ម៉ឺន នឹងស្រូវអង្ករស្បៀងអាហារ ១ ពាន់រទេះ លើកទៅដល់ដែនស្រុកអ៊ីជៀងជិតស្រុកអ៊ីជីវដែលឡេវពីនៅ ៗ

ឯហាន់សៀមដែលលីប៉ោឲ្យទៅឈរស្រុកគិនតោ នឹងអៀវហងដែលទៅឈរស្រុកឡងអៀប្រព្រឹត្តសេចក្តីអាក្រក់ ធ្វើជាចោរដើរទៅឆក់ដណ្តើមប្លន់ យករបស់ទ្រព្យបណ្តារាស្ត្រគ្រប់ភូមិលំនៅ ៗ មានមនុស្សនាំយកសេចក្តីនោះមកជំរាបឡេវពីៗ ក៏ពិគ្រោះនឹងគួនអ៊ូ, សៀវហ៊ុយថា "ឲ្យទៅអញ្ជើញហាន់សៀមនឹងអៀវហងមកស៊ីលៀង . បើអ្នកទាំងអស់គ្នាឃើញយើងពោលពែងវេលាណា ត្រូវអ្នកទាំង ២ ហួតក្រប៊ីកាត់ក្បាលហាន់សៀមនឹងអៀវហងចេញ" ហើយក៏ប្រើបំរើទៅអញ្ជើញហាន់សៀម, អៀវហងមកស៊ីលៀង ៗ លុះស៊ីផឹកឆ្អែត ឡេវពីធ្វើជាស្រវឹងពោលពែងស្រាចេញ ៗ ឯគួនអ៊ូ, តៀវហ៊ុយដែលឈរកាន់ក្រប៊ីក្បែរឆាក ក៏ស្ទុះចូលមកយកក្រប៊ីកាត់កហាន់សៀមនឹងអៀវហងស្លាប់នៅទីនោះ ទទួល

មានទាហានចូលមកជំរាបឡៅពីថា ចូឆូនឹងលើកទ័ពទៅវាយស្រុកឡាំយ៉ុង ឥឡូវមកដល់ដែនស្រុកអ៊ុជៀងហើយ ៗ ឡៅពីដឹងដូច្នោះ ក៏ប្រមូលសេនាទាហានលើកចេញទៅជួបនឹងចូឆូ ឲ្យយួរទាំងក្បាលហាន់សៀមទឹងអៀវហានចូលទៅផង ចូឆូក្រឡេកឃើញឡៅពីក៏ចេញមកទទួល គំនាប់គ្នាតាមយសសក្តិតូចធំ ៗ ឡៅពីឲ្យយកក្បាលហាន់សៀមទឹងអៀវហានបង្ហាញចូឆូហើយនិយាយថា ខ្ញុំធ្វើការគ្រានេះខុសណាស់ សូមមហាឧបរាជអភ័យទោសម្តងចុះ ៗ

ចូឆូឆ្លើយថា "ដែលអ្នកធ្វើការបានការដូច្នេះល្អណាស់ហើយ ព្រោះរាស្ត្រដែលមានសេចក្តីក្តៅក្រហាយទាំងប៉ុន្មាន ក៏បានសេចក្តីសុខសប្បាយ ដោយសារដំរិះប្រាជ្ញាអ្នក ហេតុម្តេចអ្នកមកថាបានសេចក្តីខុសវិញ" ដូច្នេះហើយឲ្យរង្វាន់បំណាច់ដល់ឡៅពីជាច្រើនហើយនាំឡៅពីលើកទ័ពទៅដល់ជិតស្រុកឈីជីវដែលលីប៉ោនៅនោះ ៗ

លីប៉ោដឹងថា ចូឆូលើកទ័ពមកក៏ចេញទៅទទួលចូឆូ ៗ និយាយនឹងលីប៉ោថា "ប្រសិនបើយើងធ្វើការនេះបានសម្រេចហើយ យើងនឹងក្រាបទូលព្រះចៅហៀនតេឲ្យតាំងអ្នកជាធំ" ហើយនិយាយល្បួងលួងលោមលីប៉ោជាច្រើន ៗ លីប៉ោមានសេចក្តីត្រេកអរ ក្រោកឡើងនូវគំនាប់ចូឆូដោយគោរព ៗ ចូឆូក៏ចាត់ហែហ្វូទុនទឹងអ៊ុតឹមជានាយទ័ពស្រួច ចាត់ឡៅពីជានាយទ័ពស្តាំ ចាត់លីប៉ោជានាយទ័ពឆ្វេង ខ្លួនចូឆូឯងជាមេទ័ពហ្លួងលើកទៅវាយស្រុកឡាំយ៉ុង ៗ

ពេលនោះអ៊ួនសុតដឹងថា ចូឆូលើកទ័ពមក ក៏ចាត់កៀវសេនឲ្យលើកទាហាន ៥ ម៉ឺន ចេញទៅរង់ចាំតទល់នៅផ្លូវតំបន់ឈើវឈុន ។ កៀវសេនក៏លើកទាហានចេញពីស្រុកទៅ ទទួលកងទ័ពហែហូទុនលើកមកដល់ ។ កៀវសេនក៏បំផ្លាយសេះចូលច្បាំងនឹងហែហូទុនបាន ៣ ក្បួន ។ ហែហូទុនយកទួនបាក់កៀវសេនធ្លាក់ពីសេះស្លាប់ ។ ទាហានទាំងពួងក៏នាំគ្នារត់ចូលទៅក្នុងស្រុកវិញ ។

ឯស៊ុនសិកដែលនៅក្នុងស្រុកកាំងតាំងដឹងថា ចូឆូលើកទ័ពទៅវាយស្រុកឡាំយ៉ុង ហើយក៏ចាត់តែងប្រមូលសេនាទាហានជាច្រើន លើកទៅស្រុកឡាំយ៉ុងតាំងនៅទិសខាងលិច ។ ចូឆូដឹងថា ស៊ុនសិកលើកទ័ពមកហើយ ក៏ចាត់លីធៀ៉ទៅតាំងទ័ពនៅទិសខាងកើត ចាត់ឡេ្យាពី, គួនអ៊ី, តៀវហ៊ុយទៅបោះទ័ពពីទិសខាងត្បូង ខ្លួនចូឆូឯងនឹងសេនាទាហាន ៧០ ម៉ឺន ទៅតាំងបន្ទាយនៅទិសខាងជើង ហើយឲ្យសញ្ញាគ្នាថា ឲ្យលើកចូលឡោមព័ទ្ធជុំវិញស្រុកឲ្យព្រមគ្នា ។

អ៊ួនសុតឃើញកងទ័ពចូឆូលើកឡោមព័ទ្ធជុំទាំង ៤ ទិសដូច្នោះហើយ ក៏ប្រឹក្សានឹងសេនាទាហានថា វេលានេះសត្រូវចូឆូធំពន្លឹក អ្នកទាំងពួងនឹងយល់ឃើញដូចម្តេច? ។ អៀវកៃជៀងឆ្លើយថា ស្រុកយើងពេលនេះ បណ្តារាស្ត្រកំពុងអត់ឃ្លានស្បៀងអាហារ បើនឹងគិតគ្នាលើកទ័ពទៅតទល់នឹងចូឆូមិនបានទេ ព្រោះទាហានខាងយើងមានសេចក្តីលំបាកច្រើន

ណាស់ សុំឲ្យលោកប្រុងប្រៀបរៀបចំសេនាទាហានឲ្យនៅត្រួតត្រារក្សាស្រុកឲ្យមាំមួនពីខាងក្នុង ឯខ្លួនលោកត្រូវនាំគ្រប់គ្រួថយទៅតាំងនៅតំ-បន់ហ្លួយណាំ ដើម្បីនឹងបានអាស្រ័យស្បៀងអាហារ ។ អ៊ួនសុតយល់ឃើញត្រូវទើបចាត់ឲ្យឡោហាង ១, ង៉ាក់ជីវ ១, លៀងកង ១, តាន់គី ១, នឹងទាហាន ១០ ម៉ឺននៅរក្សាស្រុកឡាំយ៉ុង ហើយអ៊ួនសុតក៏នាំទាហាននឹងគ្រប់គ្រួទាំងពួង ថយទៅនៅឯតំបន់ហ្លួយណាំតាមពាក្យអៀវតៃជៀងដំពបនោះ ។

ប៉ូចូមិនបានដឹងថា អ៊ួនសុតរត់ចេញពីស្រុក ក៏ឲ្យទាហានឡោមព័ទ្ធជុំវិញ ។ ឯឡោហាង, ង៉ាក់ជីវ, លៀងកង, តាន់គីដែលនៅរក្សាស្រុកនោះ ក៏មិនហ៊ានចេញច្បាំងនឹងប៉ូចូ ។ ព័ទ្ធស្រុកទុកយូរប្រហែល ១ ខែ-ឆ្ងាយទាល់តែអស់ស្បៀង ទើបប្រើមនុស្សឲ្យទៅខ្ចីស្បៀងស៊ុនសិកខាងទ័ពទូក បានស្រូវ ១០ ម៉ឺនថាំង ប៉ូចូក៏ឲ្យនាំស្រូវទៅប្រគល់ឲ្យអងហោដែលជានាយជង្រុកស្រូវ ។ (មានត)

**សង្គ្រាមកើតដោយហេតុ ៣ យ៉ាង**

ជនធ្វើសង្គ្រាមព្រោះតែហេតុ ៣ ប្រការ គឺ ដែនដី ១ មិត្រ ១ នឹងមាសប្រាក់ ១ បើឥតមានហេតុទាំង ៣ នេះ ឬ ហេតុណាមួយទេ គេមិនធ្វើសង្គ្រាមសោះឡើយ ។

ទីណាមិនមានផលចំរើនច្រើនទេ ទីនោះមានតែសេចក្ដីវិនាសម្យ៉ាង អ្នកមានប្រាជ្ញាមិនព្រមបង្កើតសង្គ្រាមក្នុងទីនោះទេ ។

បញ្ញតន្ត្រៈ

# រឿងអារក្សថ្លែងរឿងម្តៃច្រាំ

## លោកប៉ាយ-ប៊ុក ក្រមការ

*ប្រែពីភាសាបារាំងមកជាខ្មែរ*

(តមក)

---

## រឿងទី ១៦

*អារក្សពោលថា: បពិត្រមហារាជពិរ-ពិក្រមាជិត, មានទីក្រុងមួយ ឈ្មោះចន្ទ្រសេខរ (Chandrashekhar) ។ ប្រជាកស្ត្រម្នាក់នៅទីក្រុងនេះគឺនាយពាណិជឈ្មោះរតនទត្ត ' (Ratandatt), គាត់មានបុត្រីម្នាក់នាមនាងអ៊ុនមទិនី (Un madini) ។ ដល់នាងមានវ័យតរុណីភាព, បិតាបានទៅក្រាបបង្គំទូលព្រះមហាក្សត្រថា:*

*"សូមទ្រង់ព្រះមេត្តាប្រោស, ទូលបង្គំមានបុត្រីម្នាក់ នៅក្នុងគេហដ្ឋាន ។ បើព្រះករុណាទ្រង់សព្វព្រះរាជហឫទ័យនឹងបុត្រីទូលបង្គំ, សូមទ្រង់នាំនាងយកទៅចុះ, បើមិនដូច្នោះទេ ទូលបង្គំនឹងឲ្យទៅអ្នកឯទៀត" ។*

*ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់នូវវាចានាយពាណិជ, ទ្រង់ត្រាស់បង្គាប់ឲ្យអាមាត្យចាស់ដែលទំនុកព្រះទ័យ ៣ នាក់ ឲ្យទៅមើលបុត្រីនាយពាណិជ ហើយនឹងវិលត្រឡប់មកក្រាបទូលទ្រង់ឲ្យជ្រាបក្នុងរឿងនេះ ។ អាមាត្យដល់បានទទួលព្រះរាជឱង្ការហើយក៏នាំគ្នាទៅ*

កាន់គេហដ្ឋាននាយពាណិជ ហើយមានចិត្តត្រេកអរពន់ប្រមាណដោយឃើញកូនស្រីនាយពាណិជ ប្រកបដោយរូបឆោមលោមពណ៌ស្រស់បំព្រង គេអាចពោលបានថា លំអនាងនោះគឺចាំងថែងដូចជារស្មីព្រាលផ្អៅផ្សាយចេញពីបន្ទប់គេហដ្ឋានដ៏ងងឹត ។ ចក្ខុនាងដូចជាក្អែកក្ដាន់, សក់នាងមានសភាពមូលអង្កាញ់ដូចជាពស់ញី, រោមចិញ្ចើមដូចជាខ្សែធ្នូ, ច្រមុះនាងដូចជាជំពុះសេក, ធ្មេញនាងដូចជាគជ់ខ្សែងសាមសិបពីរដាក់តម្រៀបគ្នា, បបូរមាត់នាងមានសំបុរក្រហមឆ្អៅដូចជាសាច់កាលីបាស្ស (Calebasse ប្រែហៅលជាផ្ទឹក), កនាងដូចក្រពាប, ដងខ្លួននាងដូចខ្ញារចិន, ដៃ-ជើងនាងដូចបុប្ផាឈូកក្រពុំ ។ នាងមានភក្ត្រដូចព្រះចន្ទ, សម្បុរដូចផ្កាចម្ប៉ា, ដំណើរដូចក្ងាន ហើយសព្ទសូរសំឡេងដូចជាបក្សាកោកិល ( Coucou indien, Cuculus Indiens ប្រែហៅលជាសត្វកវែក ) ។ នាងទេវធីតានៅស្ថានសួគ៌ មានសេចក្ដីជឿងឆ្ងល់ជាពន្លឹកចំពោះសុក្រិតភាពនៃរូបកាយរបស់នាង គឺល្អគ្មានខ្ចោះ ល្អគន់ព្រមទាំងល្អធេត ។ ដល់ឃើញរូបនាងមានសភាពល្អឯកដូចនេះ, ពួកអាមាត្យក៏ពោលថា: “ បើស្ត្រីមួយមានលក្ខណៈរូបវិសេសថ្លៃថ្លាចូលទៅក្នុងមហាប្រាសាទនៃព្រះមហាក្សត្រនៃយើង មុខជាទ្រង់លុះក្នុងកណ្ដាប់ដៃស្ត្រីនេះមិនខាន, ទ្រង់ទៅជាទាសករនាង ហើយភ្លេចលែងនឹកនាដល់ព្រះរាជអាណាចក្រព្រះអង្គ ព្រោះហេតុដូចនេះ ត្រូវតែយើងទៅក្រាបទូលទ្រង់ថាកញ្ញានេះមានរូបកាយអាក្រក់ មិនសមរម្យទៅតាមព្រះរាជបំណងសោះឡើយ ។

ដល់សម្រេចសេចក្ដីដូចនោះហើយ ពួកអាមាត្យក៏វិលត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ក្រាបទូលព្រះមហាក្សត្រថា: "កញ្ញាដែលទូលបង្គំបានឃើញនោះ មិនសមរម្យគួរនឹងឲ្យធ្វើជាព្រះអគ្គមហេសីព្រះអង្គឡើយ" ។ ដល់ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់នូវពាក្យអាមាត្យ, ទ្រង់ក៏បានតាក់អាមាត្យឲ្យទៅជូនដំណឹងនាយពាណិជថា មិនព្រមធ្វើព្រះរាជសមរសនឹងបុត្រីនោះទេ ។

ដល់វិលត្រឡប់ទៅគេហដ្ឋានវិញ, រតនទូត្តនាយពាណិជក៏បានឲ្យបុត្រីខ្លួនរៀបវិវាហមង្គលការនឹងលោកបាលភទ្រ ( Balbhadr), ជាអគ្គបញ្ជាការកងទ័ពព្រះមហាក្សត្រ ហើយនាងក៏រស់នៅជាមួយនឹងលោកមេទ័ពតមក ។

ដូនកាលមួយថ្ងៃ, គេបានពោលថា ព្រះមហាក្សត្រទ្រង់ស្ដេចយាងតាមផ្លូវជាមួយនឹងពួកសេនាទាហាន, ហើយនាងអ៊ុនមទន្ទីនៅលើពនហាលគេហដ្ឋានរបស់ខ្លួន នាងពាក់គ្រឿងអលង្ការ, ក្រឡេកទៅចំព្រះមហាក្សត្រ, ព្រះនេត្រទ្រង់នឹងចក្ខុនាងក៏ប៉ះគ្នា ។ ព្រះមហាក្សត្រទ្រង់ព្រះតម្រិះក្នុងព្រះទ័យថា នាងនេះជានាងធីតាព្រះអាទិទេព, ឬស្រីទេពអប្សរនៅស្ថានសួគ៌ ឬជាកញ្ញាបុត្រីមនុស្សសាមញ្ញ ។ ក្នុងមួយរំពេចនោះ ស្នេកនាមរបស់នាង គឺលំអរូបឆោមស្រស់ប្រិមប្រិយនាងចូលទៅធ្វើឲ្យព្រះទ័យព្រះមហាក្សត្ររំជួលជាខ្លាំង ហើយទ្រង់ស្ដេចយាងវិលត្រឡប់

ទៅព្រះបរមរាជវាំងវិញ ។ នាយទាហានចាំក្លោងទ្វារព្រះបរមរាជវាំងបាន
ឃើញព្រះករុណាទ្រង់ក្រៀមក្រំដូច្នោះ ក៏ក្រាបបង្គំទូលសួរទ្រង់ថា ទ្រង់
ព្រះអាពាធឬ? ។

ព្រះមហាក្សត្រទ្រង់មានបន្ទូលទៅកាន់នាយចាំទ្វារថា: "ឥឡូវនេះ
យើងបានត្រាច់ទៅតាមផ្លូវ, យើងបានឃើញស្ត្រីម្នាក់មានរូបឆោមលោម
ពណ៌ស្អាតនៅខាងកនហាលគេហដ្ឋានផ្ទះមួយ ។ យើងមិនអាចដឹង
បានថាជាស្រីទេពអប្សរស្ថានសួគ៌, ឬ ទេវនារី (fée) ឬ ស្ត្រីសាមញ្ញ
តែសុភនាមរបស់នាងបានធ្វើឲ្យយើងរំជួលចិត្តជាខ្លាំង ហើយយើងព្រួយ
បារម្ភពន់ពេក" ។

នាយចាំទ្វារក៏ក្រាបទូលព្រះមហាក្សត្រថា: "បពិត្រមហារាជ
សូមទ្រង់ព្រះមេត្តាប្រោសទូលបង្គំ, ឯនារីនោះជាបុត្រីនាយពាណិជ
រតនួត ហើយនាយពាណិជនេះបានរៀបវិវាហមង្គលការនឹងលោកបាល-
កទ្រ អគ្គបញ្ជាការកងទ័ពព្រះអង្គ" ។

ព្រះមហាក្សត្រមានបន្ទូលថា: "មនុស្សដែលយើងប្រើឲ្យទៅ
ពិនិត្យនាងនេះកុហកយើង" ហើយទ្រង់ត្រាស់បង្គាប់ទៅចុពទរ (chôbdar)
អ្នកទទួលកៀវឲ្យទៅហៅអាមាត្យនោះមក ។ នាយចុពទរ បានទទួល
ព្រះរាជបង្គាប់ភ្លាម ក៏បានទៅអញ្ជើញអាមាត្យនោះ ។ កាលណា
អាមាត្យមកដល់ចំពោះព្រះភក្ត្រព្រះមហាក្សត្រ ។ ទ្រង់មានព្រះបន្ទូលថា:

"យើងបានឲ្យអ្នកឯងទៅបំពេញបេសកកម្មមួយ, ហើយអ្នកឯងមិនបានប្រតិបត្តិតាមបំណងយើង, តែអ្នកឯងត្រឡប់ជាធ្វើកលឧបាយក្នុងចិត្តពោលកុហកយើង អ្នកឯងបានមកប្រាប់យើងជាពាក្យមិនពិត ។ យើងបានឃើញឥឡូវនេះ នាងកញ្ញានោះនឹងភ្នែកយើង ។ នាងនេះស្អាតល្អប្រិមប្រិយជាសុក្រិត ហើយនាងនេះគ្មានស្ត្រីណាយកមកប្រៀបធៀបនឹងលំអបានឡើយ" ។

អាមាត្យក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា: "ព្រះអង្គទ្រង់មានព្រះរាជឧត្តរនោះពិត ។ តែសូមទ្រង់ព្រះសណ្ដាប់ទូលបង្គំអំពីហេតុដែលទូលបង្គំទាំងអស់គ្នាប្រែជាក្រាបបង្គំទូលព្រះអង្គថា នាងនេះគ្មានសម្រស់គួរឲ្យចេតនា ។ ទូលបង្គំទាំងអស់គ្នាបានគិតគ្នាថា បើស្ត្រីមានលំអយ៉ាងនេះចូលនៅក្នុងមហាប្រាសាទព្រះអង្គ ៗ មុខជានៅក្នុងអំណាចស្ត្រីនេះហើយទ្រង់នឹងបោះបង់ចោលកិច្ចការរាជការក្នុងព្រះរាជអាណាចក្រ, ហើយរាជសម្បត្តិក៏នឹងវិនាសដោយហេតុនេះមិនខាន" ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់នូវវាចាអាមាត្យ, ទ្រង់មានព្រះបន្ទូលថា: "អ្នកឯងពោលនេះជាវាចាប្រកបដោយវិចារណញ្ញាណពិត" ។ តែទ្រង់ព្រះតម្រិះទៅស្ត្រីនោះជានិរន្តរ៍យប់ថ្ងៃ ទ្រង់ផ្ទុំមិនលក់, ព្រួយព្រះរាជហឫទ័យពន់ពេក ។

តែបាលកទ្រមកដល់ ហើយក៏ធ្វើអញ្ជលីកម្មចំពោះព្រះមហាក្សត្រ, ហើយក្រាបបង្គំទូលថា: "បពិត្រមហារាជ, ទូលបង្គំ ជាទាសាព្រះអង្គ; នាងអ៊ុនមទន្ទីជាទាសីព្រះអង្គ ។ ហេតុម្តេចក៏ព្រះអង្គទ្រង់ព្រយព្រះរាជហឫទ័យដោយហេតុនាង? សូមទ្រង់ត្រាស់បង្គាប់ឲ្យនាងចូលមកគាល់ព្រះអង្គក៏ជាការស្រេច" ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់អគ្គបញ្ញាការកង់ទ័ព ទ្រង់ព្រះក្រោធជាខ្លាំង ព្រោះជាអករណីយកិច្ចមិនគួរធ្វើ, មិនគួរហៅប្រពន្ធអ្នកដទៃមកជិតខ្លួន ។ ទ្រង់មានបន្ទូលថា ហេតុម្តេចក៏អ្នកឲ្យយើងធ្វើដូចនេះ? អ្នកឯងយល់ថាយើងគ្មានសាសនា, បានជាឲ្យយើងប្រព្រឹត្តបាបអកុសលបែបនេះ? ។ ប្រពន្ធអ្នកដទៃទុកដូចជាមាតា ហើយកោតទ្រព្យអ្នកដទៃមិនមានតម្លៃស្មើនឹងកក់ផង ។ ចូរអ្នកស្តាប់យើង ។ ជាមនុស្សយល់តម្លៃអាត្មន៍អ្នកដទៃ, ដូចជាតម្លៃអាត្មន៍របស់ខ្លួន" ។

បាលកទ្រក្រាបបង្គំទូលថា: "នាងនេះជាទាសីទូលបង្គំ ។ ដែលទូលបង្គំថ្វាយទៅព្រះអង្គ, នាងនេះមិនមែនជាប្រពន្ធអ្នកដទៃទេ" ។

ព្រះមហាក្សត្រត្រាស់ថា: "បើយើងប្រព្រឹត្តបែបនេះ, លោកមុខជាបន្ទោសយើងកន្លងកាលជាអនាគត ។ យើងមិនធ្វើដូចនេះទេ" ។

លោកបាលកទ្រក្រាបបង្គំទូលថា: "ទូលបង្គំនាំនាងនេះទៅក្រៅគេហដ្ឋានទូលបង្គំ ។ ធ្វើនាងនេះឲ្យទៅជានាងដកទង នឹងនាំចូលមកថ្វាយព្រះអង្គ" ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា : " បើអ្នកឯងធ្វើស្ត្រីសុចរិតទៅជានាងជកទង, យើងនឹងធ្វើទោសដល់អ្នកឯង" ។

ក្នុងពេលនោះ ព្រះមហាក្សត្រទ្រង់មានព្រះទ័យឈ្លក់ដោយកាមតណ្ហា:ទៅកាន់នាងអ៊ុនមទិនី, ក៏ទ្រង់ទិវង្គត ១០ ថ្ងៃក្រោយតមក ។

បាលកទ្រក៏ទៅសួរលោកគ្រូរបស់លោកថា: " ព្រះមហាក្សត្រជាចៅហ្វាយខ្ញុំបាទទិវង្គតហើយ ដោយទ្រង់ស្នេហានាងអ៊ុនមទិនី តើឲ្យខ្ញុំបាទធ្វើម្តេច, សូមលោកគ្រូមេត្តាឲ្យឱវាទមកខ្ញុំបាទ " ។

លោកគ្រូតបទៅបាលកទ្រវិញថា: "ករណីយកិច្ចនៃទាសាត្រូវតែអនិច្ចកម្មក្រោយចៅហ្វាយនាយ " ។

លោកមេទ័ពបានស្តាប់នូវឱវាទគ្រូ ក៏ទៅកាន់ព្រះមេរុដែលគេបូជាព្រះមហាក្សត្រ ។ ក្នុងពេលដែលគេរៀបចំព្រះសពក្នុងព្រះមេរុនោះ បាលកទ្រក៏ងូតទឹកហើយសូត្រធម៌ ហើយដល់បូជាព្រះសព លោកក្រោកឈរឡើង, បែរមុខទៅរកព្រះអាទិត្យ, ដៃថ្វាយបង្គំពោលថា:

" ឱទេវ! ខ្ញុំសូមថាបើខ្ញុំត្រាច់រង្គាត់ក្នុងវដ្តសង្សារភពណា ខ្ញុំសូមឲ្យបានបម្រើចៅហ្វាយតែមួយនេះ ហើយរំឭកគុណូបការដែលព្រះអង្គធ្វើចំពោះខ្ញុំ" ។ ដល់ពោលរួចស្រេច, បាលកទ្រក៏ឱនក្បាលលោតទៅក្នុងភ្លើង ។

នាងអ៊ុនមទីនី ដល់ភ្ជាប់ថាស្វាមីនាងទទួលមរណភាព, នាងក៏បានទៅសួរលោកគ្រូនាងថា: "លោកគ្រូ, តើករណីយកិច្ចស្ត្រីនោះយ៉ាងណា?"ៗ

លោកគ្រូតបថា: "ភរិយាប្រកបដោយអភិជនភាព កាលណាភរិយានោះមានចិត្តស្មោះស្ម័គ្របម្រើបុរសណា ដែលបិតាមាតាបានប្រគល់ឲ្យជាស្វាមី ៗ គេបានសរសេរទុកក្នុងសៀវភៅពិសិដ្ឋថា ភរិយាធ្វើឲ្យអាយុជីវិតខ្លី បើនាងនេះអត់អាហារហើយប្រព្រឹត្តធ្វើទុក្ខបាបរូបកាយរបស់ខ្លួនក្នុងពេលដែលស្វាមីនាងនៅរស់នៅឡើយ, ហើយដល់នាងនេះលះបង់អាយុសំខាន់ទៅៗ កើតក្នុងស្ថាននរក ៗ គេបានសរសេរថា បើស្វាមីនោះមានសភាពអាក្រក់យ៉ាងណាក៏ដោយ, នាងនេះអាចយោងខ្លួនឯងរួចពីទុគ៌តភព ដោយបម្រើស្វាមីចិត្តស្មោះត្រង់ ហើយបើភរិយាណាបានបំពេញករណីយកិច្ចហៅថា សតិ (Sati) ជំហានដែលនាងឈានទៅកាន់ទីបញ្ចាមានតម្លៃស្មើគ្នានឹងពលីកម្មសេះមួយ ៗ បើទុកជាស្ត្រីនោះមានគុណសម្បត្តិយ៉ាងណា ក៏មិនស្មើនឹងគុណធម៌ "សតិ" នេះសោះឡើយ" ៗ

នាងអ៊ុនមទីនីបានស្តាប់នូវឱវាទលោកគ្រូហើយ នាងបានផ្ចិតផ្ចង់ចិត្តស្ងប់ស្ងាត់ ហើយក៏បរិច្ចាគទ្រព្យសម្បត្តិសំខាន់ទៅពួកព្រាហ្មណ៍ ហើយនាងក៏អញ្ជើញទៅកាន់ព្រះមេរុ ហើយបែរមុខទៅខាងអរុណរះ

ពោលថា: "ឱព្រះអាទិទេព! ខ្ញុំម្ចាស់ជាទាសីព្រះអង្គក្នុងជីវភាពអនាគត" ។ ដល់នាងពោលដូចនេះ នាងក៏ស្ទុះទៅអង្គុយលើព្រះមេរុនោះ រូបកាយនាងក៏ឆេះរលាយអស់គ្មានសល់ ។

ដល់អារក្សថ្លែងរឿងនេះចប់សព្វគ្រប់ហើយ ក៏ក្រាបទូលសួរមហារាជថា: "ឱមហារាជ! តើអ្នកណាមានគុណសម្បត្តិជាងគេ?"

ព្រះបាទពារ·ពិក្រមាជិតមានព្រះបន្ទូលថា: "ព្រះមហាក្សត្រ" ។

អារក្សក្រាបទូលសួរព្រះអង្គថា: "ព្រោះហេតុអ្វី?" ។

មហារាជមានព្រះបន្ទូលថា: "ព្រះមហាក្សត្របានលះបង់នូវនារីប្រពន្ធអគ្គបញ្ញាការកងទ័ព ដែលគេយកមកថ្វាយព្រះអង្គហើយ ស៊ូលះបង់ជីវិត តែបានស្រោចស្រង់នូវព្រះរាជកិត្តិយស ។ ករណីយកិច្ចអ្នកបំរើ គឺត្រូវតែធ្វើពលិកម្មនូវជីវិត ព្រោះចៅហ្វាយរបស់ខ្លួន ហើយករណីយកិច្ចរបស់ភរិយា គឺស៊ូមរណភាពនៅលើប៉ាឆាដោយសេចក្តីស្នេហាចំពោះស្វាមី ព្រោះហេតុដូចនេះ បានជាព្រះមហាក្សត្រទ្រង់មានគុណសម្បត្តិជាងអ្នកឯទៀត" ។

អារក្សបានស្តាប់ព្រះបន្ទូលមហារាជ ក៏វិលត្រឡប់ទៅព្យួរខ្លួនលើរុក្ខជាតិវិញ ហើយមហារាជបានទៅទាញយកអារក្សនោះមកវិញ លីលើព្រះអង្សាហើយទ្រង់នាំទៅ ។

ចប់រឿងទី ១៦ មានរឿង ១៧ តទៅទៀត ។

# រឿងស្លាប់ព្រោះជាតិ

មាន ៣ ឈុត

លោក គង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(តមក)

---

ឆាកទី ៦

## ភគី-វន្ធី-វណ្ណនារី-ភគា

ភគី

ឱ! លោកយាយៗ គិតរៀបចំការលោកប៉ាខ្ញុំ ឲ្យមានប្រពន្ធទៀតឬ?ៗ

វន្ធី

អើ អញគិតរៀបយ៉ាងឆាប់ គឺរៀបក្នុងថ្ងៃស្អែកនេះឯង តើឯងចូលចិត្តឬទេ? ៗ

ភគី

ទេ លោកយាយអើយ! អាណិតតែខ្ញុំទៅ ខ្ញុំមិនអាចទ្រាំនឹងបំរើម្ដាយចុងមួយទៀតទេ ខ្ញុំស្អប់ណាស់ម្ដាយចុងនោះ ខ្ញុំគ្មានចូលចិត្តបន្តិចទេ ៗ

វន្ធី

នែ! ចៅឯងក៏ឆោតអ៊ីម្ល៉េះ? ម្ដាយចុងឯណាថា, ម្ដាយចុងដែលយាយប្រុងនឹងរៀបការឲ្យប៉ាឯងនេះ ប្រសើរណាស់ ចិត្តគេល្អណាស់

ទៅ ! គេមិនមែនចិត្តប្រកបដោយទោសៈ មោហៈ ច្រើននោះទេ ។ គេអ្នករៀនសូត្រចេះដឹងជ្រៅជ្រះណាស់ពៅ! ។ គេរៀនជាប់ដល់ " សញ្ញាប័ត្រមធ្យមសិក្សា " ទៅហើយ ហើយគេបានធ្វើរាជការមក បីឆ្នាំហើយ ។ ប្រាក់ខែគេទាំងពាន់ៗ ឪពុកម្ដាយគេអ្នកមានសម្បត្តិ សម្បើមណាស់ ។

## រាគី

ទេ លោកយាយ! អាណិតតែខ្ញុំទាំងពីរនាក់នេះទៅ! ខ្ញុំមិន ព្រមឲ្យលោកប៉ាយកប្រពន្ធទៀតទេ ខ្ញុំស៊ូដាំបាយស្ងោរលោកប៉ាខ្ញុំ ។ ពីព្រោះម្ដាយចុង សូមលោកយាយជ្រាប មុនដំបូងគេធ្វើល្អនឹងយើង ណាស់ តែដល់យូរបន្តិចទៅ សឹងថាមួយឆ្នាំមិនទាន់ទេ! គេមុខតែ នឹងស្អប់ខ្ញុំទាំងពីរនាក់នេះហើយ ។ តែកាលណាប៉ាខ្ញុំស្រឡាញ់គេមែន ទែនទៅ គេធ្វើបាបខ្ញុំហើយ ខ្ញុំមុខតែនឹងទទួលសេចក្ដីវេទនាដូចពាក្យ ទំនួញក្មេង នៅក្នុងសៀវភៅបឋមវិជ្ជាខេមរភាសាថា: "កូនអើយឥតម៉ែ ឥតមានគេថែ ដូចម៉ែផងខ្លួន" យ៉ាងដូច្នេះជាដើម ។

## រិទ្ធី

ទេ! សំដីឯងទាំងនេះ មិនមែនជាការពិត ការមែននោះទេ! រឿង ដែលឯងនាំមកនិយាយនេះ គឺគេចេះតែវាយត្ពុដាក់ឲ្យពេញសៀវភៅ ទៅទេ ឯងកុំទៅជឿធ្វើអ្វី មិនមែនជារឿងពិតទេ, ឯរឿងពិតនោះ

គឺដូចជាពាក្យគេថា: "ឯម្ដាយចុង ទំនុកបំរុង ឲ្យទៅរៀនសូត្រ ឲ្យបានចេះដឹង ដោយចិត្តគេស្លូត ឲ្យទៅរៀនសូត្រ បានបុណ្យបានស័ក្តិ" យ៉ាងដូច្នេះជាដើម ទើបគេហៅថាពាក្យអ្នកប្រាជ្ញប្រដៅ ។

ភាគី

ទេ លោកយាយ! ខ្ញុំរៀនមកដប់ឆ្នាំហើយ ខ្ញុំប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សាក្នុងឆ្នាំនេះហើយ ខ្ញុំមិនដែលឃើញសៀវភៅខ្មែរឯណា គេអធិប្បាយរឿង ដូចលោកយាយមានប្រសាសន៍ទេ ។ នៃ វណ្ណនារី អូន! លោកយាយគិតរៀបចំប៉ាយើង ឲ្យមានប្រពន្ធមួយទៀតក្នុងវេលាថ្ងៃស្អែកនេះហើយ! ។

វណ្ណនារី

លោកយាយ! លោកយាយរៀបប៉ាខ្ញុំឲ្យមានប្រពន្ធទៀតឬ? ឱ ទេព្ដាអើយ! ខ្ញុំមិនព្រមឲ្យប៉ាខ្ញុំយកប្រពន្ធទៀតទេ ។ សូមអត់ទោសទៅលោកយាយ! ខ្ញុំមិនឲ្យប៉ាខ្ញុំទៅរៀបអាពាហ៍ពិពាហ៍ទេ ខ្ញុំស្អប់ណាស់ម្ដាយចុងនោះ ។

រិទ្ធី

យី! ហើយចុះប៉ាម៉េចប៉ា ក្មេងទាំងអស់ហ្នឹង! ឲ្យស្ទុះតែមារមកជែកខ្ញុំជាមួយហើយ, មើលចុះទេព្ដាអើយ គេទាំង៣នាក់នេះ ប៉ាជែកខ្ញុំហើយ ប៉ាធ្វើឲ្យខ្ញុំខ្មាសគេហើយក្នុងជាន់ហ្នឹង ។

រឿងនេះច្បាស់ជាម្ដាយក្មេកអាហ្នឹងនាំញុះញង់ហើយ គ្មាននរណាទេ, បើមិនជួយចូកជួយចែវ កុំតែយកជើងរាទឹក ៗ បើដូច្នោះខ្ញុំទៅរកគិនអ្នកតាក៏ម្ដងឲ្យស្គាល់ដៃ គឺគ្មាននរណាទេ ច្បាស់ជាយាយសង្ខិតហ្នឹងហើយ ដុតឲ្យខ្លោចពេចឲ្យឆៅ! មេកញ្ចាស់នេះបំហើយវាចង់ប្រកៀងទុកយកខ្លួនវាទៀតឬដូចម្ដេចហ្នឹង ៗ ក្ដៅចិត្តណាស់ខ្ញុំរឿងហ្នឹង ៗ

ចប់ ឈុតទី ២

## ឈុតទី ៣ ឆាកទី ១

# វន្នី-តារា

### វន្នី

អ្នក! កូនយើងវាបានជាអកត័ញ្ញូ ស្លាប់ប្រពន្ធទៅហើយ ខ្ញុំគិតពិចារណាវែងឆ្ងាយទៅ ជាវេទនាណាស់, បាយទឹកគ្មាននរណានឹងមើលខុសត្រូវឲ្យ, បើមានប្រពន្ធទៅ គ្រាន់នឹងប្រពន្ធមើលថែទាំរក្សា ៗ បើវានៅតែម្នាក់ឯងដូច្នេះ ខ្ញុំយល់ឃើញថាវាពិបាកណាស់អ្នក! ៗ

### តារា

ការត្រង់ហ្នឹង ខ្ញុំពុំហ៊ានអារកាត់ តាមតែចិត្តខ្ញុំទេ! បើអ្នកចង់ឲ្យការនេះបានសម្រេចដាច់ មានតែអ្នកហៅវាមកសួរទៅ ៗ យើងនឹងអាចធ្វើទៅតាមអំពើចិត្តរបស់យើងនោះមិនកើតទេ, មិនងាយទេអ្នក! ការនិមួយ ៗ អស់ប្រាក់ច្រើនណាស់ ៗ

វីរ្ស

ទេអ្នក! ត្រង់ការចំណាយប្រាក់នឹងការនោះ អ្នកកុំព្រួយឲ្យសោះ ស្រេចតែលើរូបខ្ញុំទាំងអស់ ។ ប៉ុន្តែខ្ញុំពិបាកចិត្តនឹងកូនហ្នឹងណាស់ ។ ខ្ញុំបានសួរវាមួយដងជាពីរដងរួចទៅហើយ វាចេះតែមានពាក្យប្រកែកប្រណាំងជាដរាប គឺវាមិនព្រមតាមពាក្យខ្ញុំសោះ, ខ្ញុំបានទៅដណ្ដឹងកូនគេហួសទៅហើយ ជានឹងរៀបការក្នុងថ្ងៃស្អែកនេះ ខ្ញុំពិបាកចិត្តណាស់អ្នក ក្នុងពេលនេះ ។

តារា

ឱ! អ្នកបានទៅដណ្ដឹងកូនគេទៅហើយ! ម្ដេចក៏អ្នកប្រញាប់អ្វីទាំងម៉្លេះ ។

វីរ្ស

អ្នក! ចិត្តខ្ញុំមិនមែននៅនឹងស្ងួតដូចជាចិត្តអ្នកទេ ។ គឺខ្ញុំមិនចង់ឲ្យកូនរបស់ខ្ញុំនៅពោះម៉ាយយូរ តែទុកយូរទៅក្រែងលោក្រមុំឬមេម៉ាយស្រពោនឯណាមួយរត់ឡើងទៅ ងាយឬ? នែអ្នក! ខ្ញុំចង់រៀបការយ៉ាងរហ័សក្នុងវេលាថ្ងៃស្អែកនេះ ។

តារា

ឱ អ្នករៀបការក្នុងថ្ងៃស្អែកនេះ! ស្លាប់ហើយក៏ប្រញាប់អ្វីម៉្លេះ សឹងតែស្ទោកកន្ទោងមិនទាន់! អ្នកធ្វើយ៉ាងដូច្នេះ ហាក់ដូចជាផ្ដុលណាស់ ។

(មានត)

# រឿងប៉ូលនិងវីរ៉ស៊ីនី

## លោកផេង-ជ្រើ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

( តមក )

---

បើកាលណាវាមកភូមិខ្ញុំ (តាចាស់) ប្រាកដជាខ្ញុំចួបវានៅក្រោមដើមល្ហុងនោះមិនខាន ៗ ថ្ងៃមួយ ខ្ញុំឃើញវាអង្គុយតែម្នាក់ឯងត្របោមក្បាលជង្គង់ មុខស្រងូតស្រងាត់នៅក្បែរដើមល្ហុង ខ្ញុំបានទៅនិយាយលេងនឹងវា ៗ ឆ្លើយមកដូចមានតទៅនេះ :

" ខ្ញុំព្រួយអីម៉េះទេ នាងក្រមុំឡាតួរទៅបានពីរឆ្នាំពីរខែហើយ, ប្រាំបីខែកន្លះហើយ នាងមិនដែលឲ្យដំណឹងអ៊ីសោះ ៗ គេជាអ្នកមានទ្រព្យហើយ ធ្វើម៉េចខ្លួនខ្ញុំជាអ្នកទុគ៌ត គេភ្លេចខ្ញុំហើយ ៗ ខ្ញុំចង់ជិះកប៉ាល់ទៅប្រទេសបារាំងរកធ្វើការបំរើស្តេច ដើម្បីសន្សំឲ្យបានប្រាក់ច្រើន កាលណាមានសម្បត្តិហើយ ខ្ញុំនឹងបានធ្វើជានាហ្មឺនធំក្នុងហ្វូង រួចខ្ញុំសុំរៀបការជាមួយនឹងនាងវីរ៉ស៊ីនី " ៗ

ខ្ញុំឆ្លើយថា: ឱសំឡាញ់! អ្នកឯងក្រែងបាននិយាយប្រាប់អញថា

**ខ្លួនមានជាតិមិនល្អ?-** ៗ

– ម្ដាយខ្ញុំប្រាប់ថាឯចិន តែចំណែកខ្លួនខ្ញុំ មិនដឹងដូចម្ដេចហៅថាជាតិទេ ខ្ញុំមិនយល់ថាខ្ញុំមានជាតិថោកជាងគេ ឬមួយគេមានជាតិថ្លៃជាងខ្ញុំនោះ ខ្ញុំមិនដឹងទេ ។

– នៅប្រទេសបារាំង ជាតិហ្នឹងហើយគេអាចហាមឃាត់ការរាជការដ៏ធំ ៗ កុំថាឡើយដល់ទៅធ្វើនាហ្មឺនធំ សូម្បីតែការងារអ្វីមួយគួរសមគឺពុំបានផង ។

– អ្នកឯងបាននិយាយប្រាប់ខ្ញុំជាច្រើនដងហើយថា មនុស្សយ៉ាងណាក៏ដោយក៏គង់បានធ្វើធំដែរនៅប្រទេសបារាំង ។ អ្នកបានរាប់ឈ្មោះមនុស្សដែលមានល្បីឈ្មោះធំ ៗ នៅស្រុកបារាំង សុទ្ធតែចេញមកពីត្រកូលតូច ៗ តែបានទៅជួយការពារផែនទឹកផែនដីឲ្យគង់វង្ស ឲ្យរុងរឿងដោយសារ ។ ឥឡូវអ្នកចង់បំភាន់ចិត្តក្លាហានរបស់ខ្ញុំ ។

– នែកូន ! អញមិនឃាត់ឃាំងអ្នកទេ អញបាននិយាយនឹងឯងពិតមែន តែរឿងហ្នឹងជាអតីតរឿង ឥឡូវនេះ វត្ថុទាំងឡាយផ្លាស់ប្ដូរប្រែប្រួលអស់ហើយ របស់អ្វីក៏មានដំឡៃដែរ នៅប្រទេសបារាំងសព្វថ្ងៃនេះ, ដីប្រទេសបារាំងត្រឡប់ទៅជាគ្រឿងនៃក្រុមអភិជន ឬមួយជាចំណែកនៃពួកទ័ពអស់លើង ។ ព្រះករុណាផែនដីប៉ីដូចជាព្រះអាទិត្យ មាននាហ្មឺនធំៗនឹងពួកទ័ពចោមរោមជុំវិញដូចពពក រកតែកូនរស្មីតូចមួយនឹងអាចចាំងមកឲ្យត្រូវអ្នកឯងស្ទើរតែពុំបានផង ។ ពីដើមក្នុងរាជការមិនសូវពិបាក

បានជាគេឃើញមានរឿងដូចអញបានប្រាប់ឯង ។ ហើយវិជ្ជានឹងសក្តិយសចំរើនឡើងគ្រប់កន្លែង ដូចជាដីទើបនឹងកានថ្មី មានជីជាតិសព្វអន្លើ ។ តែស្តេចផែនដីដែលស្គាល់មនុស្ស ហើយចេះរើសដាក់ឲ្យត្រូវសមតាមវិជ្ជារៀងខ្លួននោះក្រណាស់ ។ តាមធម្មតា ស្តេចតែងតែបណ្តោយតាមនាហ្មឺនទីងពួកទ័ពដែលនៅចោមរោមជានិច្ចកាល ។

— ចុះបើខ្ញុំរកអ្នកធំណាឲ្យជួយទំនុកបំរុងផងពុំបានឬ? ។

— បើចង់ឲ្យអ្នកធំទំនុកបំរុង ត្រូវបំរើតាមលោភចិត្តនឹងសេចក្តីសប្បាយរបស់គេ ។ អ្នកឯងទៀងតែមិនសំរេចដូចចិត្តចង់រហូត ព្រោះឯងមានជាតិមិនល្អ ហើយជាអ្នកសុចរិត ។

— ចុះបើខ្ញុំធ្វើការអ្វីប្រកបដោយចិត្តក្លាហាន ចាំសំដី ទៀងក្នុងកិច្ចទាំងពួង ឧស្សាហ៍ធ្វើការងារ ទៀងត្រង់នឹងមិត្តសម្លាញ់ បើដូច្នេះ តើខ្ញុំមិនគួរជាទីរាប់រកនៃនាហ្មឺនធំណាមួយ ដូចខ្ញុំបានឃើញមានគេធ្វើងចឹងក្នុងរឿងពង្សាវតារពីបុរាណមក ដែលអ្នកបង្រៀនឲ្យខ្ញុំអាន ។

— ឱកូនសម្លាញ់! ក្នុងសម័យពង្សក្រិកនឹងរូម៉ាំងពីដើមឯចិនមែន ព្រោះនាហ្មឺនធំមានសេចក្តីគោរពនូវអំពើល្អ ហើយយើងបានឃើញមនុស្សមានឈ្មោះល្បីទាំងហ្នឹង ច្រើនចេញមកពីត្រកូលក្រស្ត ហើយអញមិនដែលដឹងថា អ្នកមានឈ្មោះល្បីណាមួយដុះដាលឡើងមកពីអ្នកធំជួយទំនុកបំរុង ។ អំពើជាកុសលទាំងឡាយ នៅប្រទេសបារាំង ក៏តែ

មានសេចក្តីសុចរិត មុខជានឹងត្រឡប់ទៅជាធម៌ដ៏ថោកទាបប្រាកដមិនខានដូចជាអញបានប្រាប់ឯងពីមុនឯចឹង ព្រះករុណាទ្រង់លើកអំពើទាំង-ឡាយខាងលើនេះ ឲ្យជាធម៌ដ៏ឧត្តុង្គឧត្តមម្តងៗ ដោយសារទ្រង់បានប្រមះដោយព្រះអង្គឯង តែសព្វថ្ងៃនេះ ឋានៈគួរៗ ក្នុងរាជការ គេសំចៃទុកសម្រាប់ឲ្យអ្នកណាមានប្រាក់យកមកទិញ ។

- បើគ្មាននាហ្មឺនធំ ខ្ញុំទៅចូលដៃជាមួយនឹងពួកទ័ព ។ ខ្ញុំគិតគេងឲ្យសមតាមគំនិតនឹងយោបល់នៃពួកនោះ ហើយខ្ញុំនឹងជាទីស្រឡាញ់ពេញចិត្តមិនខាន ។

- បើដូច្នោះ មានតែឯងតោងធ្វើដូចមនុស្សផងទាំងពួង ហើយឯងត្រូវលះបង់នូវចិត្តទៀងត្រង់ដើម្បីស្វែងសម្បត្តិ ។

- បើឯចឹងទេ! ខ្ញុំត្រូវស្វែងរកតែសេចក្តីទៀងត្រង់ សេចក្តីពិត ។

- បើដូច្នេះ គេមិនទាន់ទាំងមានចិត្តស្នេហាផង គេមុខជាត្រូវស្អប់មុនវិញហើយ ព្រោះពួកទ័ពមិនត្រូវការនឹងពាក្យពិតប៉ុន្មាន ។ មតិទាំងប៉ុន្មាន គឺគិតឲ្យសមតែនឹងមនុស្សចិត្តលោភ ព្រោះវាគិតឲ្យបានខាងតែត្រួតពីលើគេ ។

- បើឯចឹង ខ្ញុំមិននៅតែរងទុក្ខវេទនាដូច្នេះហើយ បើត្រង់កន្លែងណាក៏ចូលមិនចុះសោះគ្រប់មុខគ្រប់ក្រសួង ។ ខ្ញុំមុខជាត្រូវនៅធ្វើការរកស៊ីតែម្នាក់ឯងក្នុងព្រៃឆ្ងាយពីវ៉ែស៊ុទីហើយ ។

ត្រង់នេះអាប៉ូលដកដង្ហើមធំ ។

– ចូរឯងយកព្រះជាម្ចាស់ទុកជាមេបា យកជាតិមនុស្សទុកជាខ្លួនឯង ។ ពួកក្រុមត្រកូលខ្ពង់ខ្ពស់ ពួកទ័ព ពួករាស្ត្រនឹងស្តេចធ្វើការអ្វីតាមអំពើចិត្តនឹងតាមចំណង់របស់គេ ត្រូវបំរើគេជាញឹកញយដោយចិត្តទុច្ចរិត ព្រះជាម្ចាស់នឹងជាតិមនុស្ស ត្រូវការពីយើងតែអំពើល្អ ។

“ ចុះហេតុអ្វីក៏ឯងចូលចិត្តចង់ឲ្យថ្កើង ញែកពីមនុស្សទាំងឡាយ ? គំនិតដូច្នេះមិនមែនជាគំនិតដែលព្រះជាម្ចាស់បង្កើតទេ ដ្បិតថាបើអ្នកកល់គ្នាមានគំនិតបែបនេះដូចគ្នា អ្នកទាំងនោះមុខជានឹងធ្វើចម្បាំងជាមួយប្រទេសជិតខាងពុំខាន ។ ត្រូវឯងចូលចិត្តបំពេញកិច្ចរបស់ខ្លួនដែលព្រះជាម្ចាស់បានដាក់ទុកឲ្យមក ចូរឯងត្រេកអរនឹងសំណាងខ្លួន គឺព្រេងវាសនានេះហើយដែលនាំឲ្យឯងមានចិត្តស្មោះត្រង់ចំពោះខ្លួន ហើយមិនបង្ខំខ្លួនកុំដូចជានាហ្មឺនធំឲ្យគេខ្វះយកសេចក្តីស្រួលពីអ្នកតូចទាប ហើយឲ្យអ្នកតូចរវេខ្វេសខ្វាសទៅរកខ្លួនដើម្បីធ្វើការចិញ្ចឹមជីវិត ។ ដើម្បីរស់នៅអ្នកត្រូវនៅក្នុងប្រទេសមានទំនងដែលខ្លួនមិនបាច់ត្រូវការបំភាន់ មិនបាច់បញ្ឆោត មិនបាច់ធ្វើខ្លួនឯងឲ្យថោកទាប កុំដូចជាអ្នកខ្លះ ស្វែងទ្រព្យក្នុងប្រទេសទុរបទឡើយ ។

(មានត)

សន្និសិទព្រះពោធិវង្ស ហួត - តាត

ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ជាប្រធាននៃគណៈប្រតិភូខ្មែរ

ថ្លែងអំពីសមាជសាកលលើកទី ២ នៃពុទ្ធសាសនា

នៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

# ពុទ្ធសាសនបណ្ឌិត្យ

(ត-ចប់)

---

កាលពីឆ្នាំ ១៩៥០, សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត ជោតញ្ញាណោ សង្ឃនាយក ជាប្រធាននៃគណៈប្រតិភូប្រទេសកម្ពុជា បាននិមន្តទៅប្រជុំធ្វើសមាជនៅក្រុងកោលម្បូ នាប្រទេសលង្កា ក្នុងការបង្កើតពុទ្ធិកសមាគមពិភពលោក ក្នុងឱកាសនោះ សម្តេចបានថ្លែងពីកិច្ចការខាងព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជា ជូនអស់លោកទាំងឡាយឲ្យបានជ្រាប ១ លើករួចហើយ ។

វេលានេះ យើងសូមថ្លែងម្តងទៀតយ៉ាងសង្ខេប ជូនអស់លោកទាំងឡាយ ដូចតទៅនេះ:

តាំងអំពីពេលក្រោយ ដែលសម្តេចព្រះមហាសុមេធាធិបតីសង្ឃ-នាយកនិមន្តត្រឡប់ពីការប្រជុំនៅលង្កាទ្វីប ទៅកាន់ប្រទេសកម្ពុជាវិញ សម្តេចបានថ្លែងពីកិច្ចការប្រជុំនោះ ថ្វាយព្រះករុណាជាម្ចាស់ជីវិតប្រទេស

កម្ពុជា ព្រមទាំងបានថ្លែងឲ្យពលរដ្ឋខ្មែរ នៅក្នុងក្រុងនិងខេត្តក្រៅបាន ស្តាប់បានយល់ នូវអត្ថការណ៍នៃពុទ្ធិកសមាគមយ៉ាងច្បាស់លាស់ ។

សេចក្ដីថ្លែងរបស់សម្តេច នាំឲ្យពុទ្ធមាមកជនទាំងឡាយ មានចិត្តត្រេកអរ កើតសេចក្ដីជ្រះថ្លាចំពោះព្រះពុទ្ធសាសនា កាន់តែមាំមួនឡើងជាងពីមុនទៅទៀត ។

ចំណែករាជរដ្ឋាភិបាល ដែលមានព្រះមហាក្សត្រិយ៍ជាប្រមុខ ក៏ខំប្រឹងជួយបំពេញកិច្ចការ ដែលទាក់ទងដល់ព្រះពុទ្ធសាសនា ឲ្យមានដំណើរជឿនទៅមុខដោយលំដាប់ ។

ឯពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគ សម្រាប់ប្រទេសកម្ពុជាដែលជាសាខាផ្នែក ១ នៃពុទ្ធិកសមាគមពិភពលោក ក៏ពួកពុទ្ធបរិស័ទបានបង្កើតហើយ សមាគមនោះទើបចាប់អនុវត្តតាំងពីចុងឆ្នាំ ១៩៥២ នេះតទៅ ។

មួយយ៉ាងទៀត, យើងយល់ថាអស់លោកទាំងឡាយគង់បានជ្រាបថា ប្រទេសកម្ពុជាសព្វថ្ងៃនេះ ជារដ្ឋមួយដ៏តូច មានប្រជាជនចំនួនជិត ៤ លាននាក់ប៉ុណ្ណោះ ។

ចំនួននេះ រាប់តាំងពីព្រះមហាក្សត្រិយ៍, ព្រះរាជវង្សានុវង្ស នឹងមន្ត្រីគ្រប់តំណែង រហូតដល់ប្រជារាស្ត្រ ពលរដ្ឋទាំងក្នុងក្រុងនិងខេត្តក្រៅ សុទ្ធតែជាអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់ ។ បើនឹងមានសល់ខ្លះក៏មិនហួសពីចំនួន ១០០ នាក់ ដែលងាកចិត្តទៅកាន់សាសនាឯទៀត ស្ទើរ

តែកំបាំងគំនិតនៃប្រជាជនពុំអាចជីកល់គ្នាថា មានខ្មែរក្រៅសាសន៍នៃព្រះពុទ្ធដូច្នោះកំសឹងថាបាន ។

អំពីចំនួនវត្តអារាមនិងបព្វជិត

វត្តអារាមខាងព្រះពុទ្ធសាសនា, សព្វថ្ងៃនេះ មានចំនួន ២.៧៦៣ វត្ត ចំណែកខាងពួកបព្វជិតទាំងភិក្ខុទាំងសាមណេរ ដែលអាស្រ័យនៅក្នុងវត្ត ដែលមានចំនួនដូចខាងលើនេះ រូបរួមទាំងអស់ក្នុងឆ្នាំនេះមានចំនួន ៨០.២៣ ២ រូប, ប៉ុន្តែចំនួននេះមិនទៀងនៅដដែលទេ ជួនកាលច្រើនជាង ជួនកាលតិចជាង ។

អំពីសាលារៀនប៉ែកខាងព្រះពុទ្ធសាសនា ព្រះមហាក្សត្រិយ៍ជាប្រមុខនៃប្រទេសកម្ពុជា ព្រមទាំងព្រះរាជរដ្ឋាភិបាលដែលជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន បានបង្កើតឲ្យមានសាលារៀន ប៉ែកខាងព្រះពុទ្ធសាសនាតាំងពី ៣០ ឆ្នាំកន្លងទៅហើយ ដរាបដល់បច្ចុប្បន្ននេះមានសាលារៀន ៣ ប្រភេទ គឺ:

១ — សាលាបាលីរង .— សាលានេះមានក្នុងក្រុងនិងខែត្រក្រៅ ជាសាលាដែលប្រជាជនសុំបង្កើតឲ្យមានឡើង សម្រាប់ឲ្យភិក្ខុសាមណេររៀនវេយ្យាករណ៍បាលី, រៀនប្រែពីបាលីជាខ្មែរ, រៀនតែងសេចក្តីខ្មែរ, រៀនលេខនព្វន្ត, រៀនពុទ្ធប្បវត្តិ ព្រមទាំងរៀនវិន័យផង ។ សាលានេះត្រូវរៀនកំណត់ ៣ ឆ្នាំ ត្រូវប្រឡងចេញពីសាលាក្នុងការ

ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ។ សព្វថ្ងៃនេះមានចំនួន ៣០០ តំបន់, មានសិស្សដែលប្រឡងចេញក្នុងមួយឆ្នាំៗ ច្រើនជាង ២.០០០ រូប ដែលបានទទួលសញ្ញាប័ត្រសម្រាប់សាលាបាលីរង ។

២ — សាលាបាលីជាន់ខ្ពស់ .— សាលានេះបង្កើតនៅក្នុងក្រុងភ្នំពេញ ជាសាលាឋិតនៅក្នុងការឧបត្ថម្ភរបស់រាជរដ្ឋាភិបាល មានព្រះមហាក្សត្រិយ៍ជាប្រមុខ ។ សាលានេះជ្រើសរើសយកសិស្ស ដែលប្រឡងចេញពីសាលាបាលីរងក្នុង ១ ឆ្នាំយក ១០០ រូបឲ្យចូលរៀន ។ សាលានេះសម្រាប់បង្រៀនបាលី, សំស្រ្កឹត ភាសាបារាំង ទីងវិជ្ជាខាងសាសនាខ្លះ ខាងផ្លូវលោកខ្លះ ។ សិស្សរៀនគ្រប់ ៤ ឆ្នាំ ត្រូវប្រឡងចេញយកសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ។ សព្វថ្ងៃសាលានេះមានចំនួនសិស្សជាង ៤០០ រូប រួមទាំងសិស្សជាតិខ្មែរ នៅប្រទេសវៀតណាម នឹងសិស្សជាតិលាវ ដែលរដ្ឋាភិបាលលាវបញ្ជូនមកឲ្យរៀនផង ។

( ក្នុងបច្ចុប្បន្នកាលនេះ រដ្ឋាភិបាលមានព្រះមហាក្សត្រិយ៍ជាប្រមុខកំពុងគិតរៀបចំពង្រីកសាលានេះឲ្យមាន ៣ ថ្នាក់ថែមទៀត គឺជ្រើសរើសយកសិស្សដែលប្រឡងចេញ មានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ហើយឲ្យរៀន ៣ ឆ្នាំតទៅទៀត ដើម្បីឲ្យពួកបព្វជិតជាសិស្សទាំងនោះបានចេះភាសាបរទេស មានភាសាបារាំងនឹងអង់គ្លេសជាដើមឲ្យបាន

មាំមួន ជាហេតុនឹងឲ្យព្រះសង្ឃមានផ្លូវប្រស្រ័យខាងព្រះពុទ្ធសាសនា នឹងនានាប្រទេសបានដោយស្រួល) ។

៣ – សាលាធម្មវិន័យ.— សាលានេះព្រះមហាក្សត្រិយ៍បានប្រជុំជាមួយនឹងរដ្ឋាភិបាល នឹងសម្តេចព្រះសង្ឃនាយក បានបង្កើតឲ្យមានឡើងក្នុងប្រទេសតាំងមូល សម្រាប់បង្រៀនធម៌នឹងវិន័យព្រះពុទ្ធ-សាសនា ។ តទៅអនាគត សាលានេះត្រូវឲ្យមានគ្រប់វត្តអារាមក្នុងប្រទេស ភិក្ខុសាមណេរគ្រប់រូបត្រូវតែរៀនខានពុំបាន ។

ព្រះមហាក្សត្រិយ៍ដែលបង្កើតសាលានេះឡើង ដោយឃើញថាមានប្រយោជន៍ធំទូលាយក្នុងព្រះពុទ្ធសាសនា ហើយឲ្យមានផលប្រសើរដល់ពលរដ្ឋក្នុងប្រទេសផង ដូចខាងក្រោមនេះ:

ក) ព្រះសង្ឃក្នុងប្រទេសតាំងមូលនឹងមានការចេះដឹងដូចគ្នា ។

ខ) កាលបើចេះដឹងដូចគ្នាហើយ ព្រះសង្ឃគ្រប់វត្តនឹងមានអធ្យាស្រ័យត្រូវគ្នា មិនខ្វែងគំនិតគ្នាខាងផ្លូវសីលធម៌តាមលំអានព្រះបរមពុទ្ធោវាទ ។

គ) កាលបើមានអធ្យាស្រ័យត្រូវគ្នាហើយ នឹងនាំឲ្យព្រះសង្ឃមានសាមគ្គីធម៌ ចេះប្រជុំគ្នា ចេះស្រឡាញ់រាប់អានគ្នា តាមលំអានព្រះធម៌វិន័យ ។

ឃ) កាលបើព្រះសង្ឃគ្រប់វត្តមានការរួបរួមគ្នាហើយ ពួកគ្រហស្ថដែលនៅជុំវិញវត្តអារាម ក៏នឹងមានសាមគ្គីធម៌ក្នុងផ្លូវសីលធម៌ផងដែរ ។

ង) កាលបើបព្វជិតនឹងគ្រហស្ថមានសាមគ្គីធម៌ហើយ សេចក្តីសុខសាន្តក៏នឹងកើតមានឡើងដែរ, បើសេចក្តីសុខសាន្តកើតមានហើយ ប្រជាជនក្នុងប្រទេសនឹងអាចបំពេញមុខការគ្រប់យ៉ាង ឲ្យបានសម្រេច ឲ្យមានសេចក្តីចំរើនឡើងតាមធម៌បាន ទាំងព្រះពុទ្ធសាសនាក៏នឹងបានរុងរឿង ។

យើងបានរៀបរាប់ពីកិច្ចការខាងព្រះពុទ្ធសាសនាក្នុងកម្ពុជរដ្ឋ ជូនអស់លោកអ្នកទាំងឡាយឲ្យបានជ្រាប់ ដោយសង្ខេបត្រឹមតែប៉ុណ្ណេះ ។

ទីបំផុតនេះ យើងសូមគុណព្រះរតនត្រ័យគឺៈ ព្រះពុទ្ធ, ព្រះធម៌ នឹងព្រះសង្ឃជួយអភិបាលរក្សាពុទ្ធិកសមាគមពិភពលោក របស់យើងទាំងអស់គ្នា នឹងអស់លោកទាំងឡាយឲ្យបានសេចក្តីសុខ - ចំរើន អស់កាលជាអង្វែងតរៀងទៅ ។

យើងសូមផ្សាយមេត្តាចិត្ត សូមសាកលលោកបានប្រកបដោយសុខភាពដ៏ទៀងទាត់ប្រាកដតាមផ្លូវធម៌ ។

ចប់

# សុន្ទរកថា

## លោកដុកទ័រគុណបាលៈបិយសេនៈម៉ាល៉ាលៈសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងពេលសមាជសាកល
លើកទី ២ នៃពុទ្ធសាសនា នៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

## ពុទ្ធសាសនបណ្ឌិត្យ

(តមក)

---

គួរសរសើរពន់ពេកចំពោះព្រះពុទ្ធសាសនា ដែលមានប្រវត្តិមិនដែលមន្ទិលសៅហ្មងដោយអករណីយកិច្ចខាងតុលាការសាសនា នឹងការណែនាំបញ្ចុះបញ្ចូលហួសប្រមាណ, នឹងការកំហែងយកប្រាក់ធ្វើមនុស្សឲ្យក្រីក លំបាក ឬដោយប្រើវិធីកំឡាចគំរាម ព្រមទាំងនយោបាយដ៏ខ្ពង់ខ្ពស់ ដើម្បីឲ្យបានអ្នកចូលច្រើន ៗ ព្រះពុទ្ធសាសនាមិនដែលណែនាំឲ្យអ្នកដទៃចូលក្នុងសាសនាខ្លួននៅទីប្រជុំជន ៗ ដោយវិធារណញ្ញាណដូចនេះ បានជាលោកដុកទ័រកុង្សសរសើរក្នុងសៀវភៅមួយនាម Buddhis, Its Essence and D veloppements ប្រែថា ព្រះពុទ្ធសាសនាចំពោះបុព្វហេតុនិងសកម្មភាព ថា: មានអធិប្រទេសជាច្រើនដែលប្រវត្តិសាស្ត្របានចារិកទុកថា ជាអធិប្រទេសកាចសាមាន្យ ដែលមានទាហានពាលទុច្ចរិត ព្រមទាំងនាក, សង្គ្រាមនិងពួកចៅក្រមជាអ្នកគ្រប់គ្រង ៗ

ប្រទេសទាំងនេះ មិនមានប្រទេសណាមួយអាចស្ថិតនៅបានបរិសុទ្ធ ៗ ម្យ៉ាងវិញទៀត មានការចលនានៃពួកសមយាចកដែលស្ម័គ្រចិត្តកប់អានខាងការក្រៃក្រដាងមានគោគទ្រព្យ បានធ្វើសច្ចាធិដ្ឋានថា លែងប្រព្រឹត្តទុច្ចរិតទាំងពិយាដសត្វ, ពួកនេះបានយកពេលឱកាសទៅគិតកិច្ចការប្លែកអស្ចារ្យហើយក៏បង្កើតនៅក្នុងហទយវត្ថុ នូវប្រទេសប្រកបដោយអច្ឆរិយភាព ដែលមិនដែលមានអ្នកណាឃើញសោះឡើយ ពួកនោះច្រើនប្រមាទមើលងាយនូវវត្ថុដែលគេទាំងអស់គ្នាកប់អាន ច្រើនពេញចិត្តនូវវត្ថុដែលគេទាំងអស់គ្នាប្រមាទ, សភាពស្លូតត្រង់ ចិត្តសប្បុរស, ការពិចារណាដោយនៅស្ងៀមស្ងាត់ ៗ តែត្រង់ណាដែលអធិប្រទេសទាំងនោះ ប្រកបដោយពលភាពកើតឡើងដោយចិត្តលោភ ស្អប់នឹងសភាពមិនពិត ស្ថិតនៅបានត្រឹមតែពីរបីសតវត្ស, ការលះបង់ចោលនូវទុច្ចរិតសព្វយ៉ាង បានដឹកនាំព្រះសង្ឃខាងព្រះពុទ្ធសាសនាឲ្យទៅកាន់សេចក្ដីចម្រើន តាំងពី ២.៥០០ ឆ្នាំមកហើយ ៗ

## ការសិក្សាព្រះពុទ្ធសាសនា

ដោយយើងជាពួកពុទ្ធបរិសទ្យ យើងមិនត្រូវភ្លេចថាព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ទ្រង់បានត្រាស់បង្គាប់ ឲ្យយើងបំពេញករណីយកិច្ចត្រង់ការផ្សាយនូវសិទ្ធិដ៏ប្រសើរនេះ ដើម្បីសេចក្ដីល្អ នឹងសេចក្ដីសុខចំពោះសត្វលោកទាំងអស់ ព្រមទាំងសុខមង្គលដល់ទេវតា នឹងមនុស្ស

ទាំងឡាយ ៗ ទាំងនេះនាំឲ្យយើងមានករណីយកិច្ចសំខាន់ ត្រង់ឲ្យស្គាល់ជាក់ច្បាស់នូវខ្លួនយើងចំពោះលទ្ធិនេះ មុននឹងផ្សាយទៅកាន់អ្នកដទៃ ៗ ហើយត្រង់នេះ យើងត្រូវស្ថិតនៅចំបញ្ហាធំមួយ គឺការអប់រំបុត្រធីតារបស់យើង ៗ ប្រវត្តិសាស្ត្របានបង្រៀនយើងថាព្រះពុទ្ធសាសនាមានគុណូបការៈត្រង់ការសិក្សានៅទីណា ដែលព្រះពុទ្ធសាសនានេះផ្សាយទៅដល់ ព្រោះថាព្រះពុទ្ធសាសនាជាសាសនាប្រកបដោយស្មើភ្លឺស្វាងរុងរឿង ហើយការសិក្សានេះជាផ្លូវសំខាន់មួយដែលនាំទៅកាន់អាកាស្វាង ៗ នៅប្រទេសដែលកាន់ព្រះពុទ្ធសាសនា, វត្តអារាមនឹងសាលាទាន គេទុកអាសនៈនេះជាសាលារៀនដែលបុត្រធីតាបានទៅសិក្សារៀនសូត្រ ដោយមាតាបិតាបង់សោហ៊ុយថ្លៃរៀន បន្តិចបន្តួចឬមិនបង់សោះក៏បាន ៗ ប្រទេសខ្លះ ដែលនៅក្នុងអនិស្សរភាពនៃបរជាតិមានការសំខាន់ចំពោះកលយុទ្ធ ក្នុងការបំផ្លាញបំបាត់នូវវប្បធម៌នៃប្រជារាស្ត្រប្រទេសនោះ ដើម្បីនឹងធ្វើឲ្យប្រជារាស្ត្រស្ថិតនៅក្រោមបង្គាប់បញ្ជាខ្លួន ៗ

មធ្យោបាយសំខាន់ដែលត្រូវប្រើ ដើម្បីនឹងសម្រេចនូវបំណងនោះ គឺកិច្ចត្រួតត្រាខាងការសិក្សា ៗ ប្រទេសជាច្រើន មានរដ្ឋាភិបាលនៃប្រទេសនោះ បានកែប្រែវិធានការនៃការសិក្សា ដែលធ្លាប់អប់រំពីអតីតកាល យកវិធានការថ្មីមកជំនួស ៗ វិធានការនោះ មាន

មូលដ្ឋានចំពោះប្រពៃណីនិយម ទីដំនៀដែលមានសភាពខុសពីចរិត និស្ស័យនៃប្រជាកស្រ្តដែលខ្លួនត្រួតត្រា ។ ទាំងនេះនាំឲ្យវិនាសសាបសូន្យនៅសាលាវត្តដែលជាទីសម្រាប់ព្រោះសាបនូវវប្បធម៌ ខាងព្រះពុទ្ធ-សាសនា ។ វិធានការបើកធំការសិក្សានេះ បានប្រគល់ឲ្យបេសកជនបរជាតិយកមកបង្ហាត់បង្រៀន ដែលមានវត្ថុបំណងចង់ឲ្យអ្នករៀននោះចូលទៅក្នុងសាសនារបស់ខ្លួន ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលបានជួយសោហ៊ុយរៀនក្នុងកិច្ចបញ្ចុះបញ្ចូលសាសនានេះ ដែលពួកបរជាតិឃោសនាផ្សាយដោយឥតអៀនខ្មាសសោះឡើយ ។

សេចក្ដីអាក្រក់ដែលកើតឡើង ដោយការប្រែប្រួលចំពោះបដិវត្តនេះមានភាពសម្បើមអស្ចារ្យ ។ ក្នុងប្រទេសទាំងប៉ុន្មាននៅទ្វីបអាស៊ី ព្រះពុទ្ធសាសនាទីងវប្បធម៌ខាងព្រះពុទ្ធសាសនាអន់ថយនូវតម្លៃ ជាលំដាប់តមក ។ កិត្យានុភាពនៃព្រះសង្ឃដែលជាអ្នកតេក្សាទុកនូវព្រះធម៌ក្នុងរយៈវេលាជាច្រើនសតវត្ស ត្រូវអន់ថយធ្វើឲ្យប្រជាកស្រ្តទាំងនោះខ្សោយ នូវសេចក្ដីកប់អាននៃបៅអាកាសវត្ត ។ បុរសនិងស្រ្តីចម្រើនវ័យវឌ្ឍនាការឡើង រស់នៅក្នុងកំស្នួលជាសម្ភារៈប្រយោជន៍ព្រមទាំងប្រយោជន៍ផ្ទាល់ខ្លួន មានចិត្តគិតទៅការប្រឡងធ្វើការក្នុងរាជការតែគួរឲ្យស្ដាយពន់ពេក បុរសនិងស្រ្តីទាំងនោះ សិតនៅក្នុងអវិជ្ជាចំពោះសាសនាទីងវប្បធម៌ ។ ជីដូនជីតានៃបុរសស្ត្រីនោះពេញចិត្តហួសជីវិត

របស់ខ្លួនទៅទៀត ។ សាសនាទីនវប្បធម៌នេះ បានធ្វើឲ្យប្រទេសទាំងនេះមាននាមល្បីល្បាញ, សម្បូណ៌ដោយភោគទ្រព្យ, សន្តិភាពហើយនិងការពេញចិត្តខាងក្នុងហទយតែ ។ តែគឺក័ពុំសំណាងល្អ ពេលដែលបញ្ចុះបញ្ចូលឲ្យចូលកាន់សាសនានេះនិងជិតផុតលេតជាអសោនគិច្ច ពិតមែនតែកិច្ចនេះ មានធ្វើដោយណាក់បំពួនទៅទិកន្លែងកេន្ទកំព្រា, មន្ទីរព្យាបាលពេត, មន្ទីរពេទ្យ, ហើយនៅមានតិចណាស់បំពោះសាលារៀនជាច្រើន ។

នៅប្រទេសក្នុងទ្វីបអាស៊ីខ្លះ លទ្ធិជាតិនិយមដែលទើបនឹងកើតឡើងជាថ្មី បានបញ្ជាក់ថា មានការសិក្សាព្រះពុទ្ធសាសនាបានផុះផុលឡើងជាថ្មី នៅប្រទេសខ្លះដូចជាកោះស៊ីឡង់, សភាពដែលកើតថ្មីនេះ បានសេចក្ដីបម្រើនជាអនេកប្បការ ។ តែបំពោះករណីយ៍ខាងលើនេះ ត្រូវព្យាយាមធ្វើដំណើរតទៅទៀត ព្រោះថាត្រូវតែមានសាលាអប់រំព្រះពុទ្ធសាសនាជាច្រើន ប្រកបដោយសោភណលក្ខណៈ បំពោះកូនប្រុសហើយនិងកូនស្រី ។ ពួកពុទ្ធសាសនិកជនមិនអាចនឹងមានចិត្តនៅស្ងៀមបាន បើកូនប្រុសនិងកូនស្រីនិមួយ ៗ មិនមានមធ្យោបាយក្នុងកិច្ចសិក្សា ដែលមានប្រយោជន៍ហើយ ត្រូវតែធ្វើគ្រប់ថ្នាក់-ជាន់ តាំងពីថ្នាក់កុមារដ្ឋានរហូតទៅដល់មហាវិទ្យាល័យ ។

(មានត)

# ពិធីប្រឡងធម្មវិន័យ

## នៅវត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប

## ព្រះមហាឧត្តមវិជ្ជា កែ-អឿន (វីរិយប្បញ្ញោ)

រៀបរៀង

---

កាលពីថ្ងៃអង្គារ ១ កើតខែបុស្ស ឆ្នាំរោងចត្វាស័ក ព.ស. ២៤៩៥ ត្រូវនឹងថ្ងៃទី ១៦ ខែធ្នូ គ.ស. ១៩៥២ មានពិធីប្រឡងធម្មវិន័យចំពោះសិស្ស ២៥០ រូប ទាំងថ្នាក់ត្រី-ថ្នាក់ទោ ដែលបានសិក្សាក្នុងសាលា-ធម្មវិន័យវត្តនានាក្នុងខេត្តសៀមរាប គឺវត្តព្រះព្រហ្មរតន៍ ១ វត្តរាជបូព៌ ១ វត្តកេស្សរារាម (ធម្មយុត្តិ) ១ ក្នុងស្រុកសៀមរាប, វត្តធម្មិស្សរារាម ១ វត្តព្រហ្មបទ្ទ ១ វត្តមុនជ្យាន ១ ក្នុងស្រុកសូទ្រនិគម, វត្តព្រះពុទ្ធ-ឯករាជ្យ ១ ក្នុងស្រុកជីក្រែង, និងវត្តធិបតី ១ ក្នុងស្រុកពួក ៗ សិស្សទាំងនោះសុទ្ធតែជាសិស្សក្រៅអំពីសិស្ស ដែលសិក្សាបំពេញវិជ្ជាធម្មវិន័យក្នុងវត្តលោកគ្រូអនុគណ គ្រប់ស្រុកក្នុងខេត្តសៀមរាប ៗ កាលប្រឡងក្នុងលើកនេះ ក្រសួងធម្មការ និងក្រសួងសម្តេចព្រះសង្ឃនាយកបញ្ជាការឲ្យប្រឡងរួបរួមក្នុងកន្លែងតែមួយ គឺយកវត្តព្រះព្រហ្មរតន៍ជាទីប្រឡង ៗ ការប្រឡងនេះ អឹកធឹកឧឡារិកណាស់ ហាក់ដូចជាមានពិធីបុណ្យមួយដ៏អស្ចារ្យ ក្នុងព្រះពុទ្ធសាសនា, ក្នុងទីវត្តទាំងមូល

ប្រដាប់ដោយទង់ជាតិ, ទង់ព្រះពុទ្ធសាសនាធំ-តូច តាំងពីមុខសាលាធម្មវិន័យដកបដល់ក្លោងទ្វារកំពែងក្រៅ: សាលាធម្មវិន័យ, សាលាបាលីថ្មី ក៏សុទ្ធតែតាក់តែងវិចិត្រតរចនា ដោយទង់ជាតិ ទង់សាសនាធំ-តូចជាលំអ, នៅសាលាធម្មសភាមានរៀបគ្រឿងសក្ការបូជា ថ្វាយចំពោះព្រះរតនត្រ័យ, នៅខាងជើងសាលាធម្មវិន័យទីងសាលាធម្មសភា មានមន្ទីរឃោសនាការតូច ១ សម្រាប់ពុទ្ធបរិស័ទចូលសម្ដា, កងមន្ទីរនេះមានតាក់តែងដោយរូបថតជាច្រើន មានរូបថតកាលបុណ្យព្រះសារីរិកធាតុ និងព្រះអរហន្តធាតុដង្ហែមកកាន់ព្រះរាជធានីភ្នំពេញជាដើម; នៅវេលាយប់ពិធីបុណ្យនេះមានទស្សនីយភាពដ៏រុងរឿងដោយចង្កៀងអគ្គិសនី បញ្ចេញរស្មី ខៀវ, លឿង, ក្រហម, ស, គួរជាទីនាំឲ្យវត្ថុឲ្យត្រេកអរពន់ពេក ។

## កម្មវិធី

ថ្ងៃទី១.— ពិធីបុណ្យនេះ បានប្រារព្ធធ្វើតាំងពីល្ងាចថ្ងៃ ១៥ ខែធ្នូ ដោយមានពុទ្ធបរិស័ទ អញ្ជើញពីវត្តនានាឆ្ងាយជិតមកជួបជុំជាច្រើនជួយឧបត្ថម្ភកងការប្រឡងនេះ, ម៉ោង ៨ កន្លះនិមន្តព្រះមហាឧត្តមរដ្ឋកែ-អឿន សំដែងធម៌ទេសនា ជាធម្មប្បដិសណ្ឋារៈ ។

ថ្ងៃទី ២.— គឺថ្ងៃ ១ កើតខែបុស្ស (១៦-១២-៥២) ម៉ោង ១១ កន្លះពុទ្ធបរិស័ទអង្គាសចង្ហាន់ដល់ភិក្ខុ-សាមណេរ ។

ម៉ោង ៣ រសៀលជួបជុំសិស្សទាំងពីរថ្នាក់ ហៅឈ្មោះសិស្សឲ្យតាមលេខតួរ ទៅអង្គុយតាមកន្លែងតុនិងបែកក្រដាសសម្រាប់ប្រឡង, សិស្សអង្គុយតាមកន្លែងរៀបរយហើយ, ពួកក្រុមមេប្រយោគមានព្រះសុមង្គលសីលាចារ្យជាអធិបតីបើកប្រយោគទី ១ គឺសាសនសុភាសិតទាំងថ្នាក់ត្រី-ទោ ដែលនៅក្នុងស្រោមបិទកាគល់ៗ ហើយសរសេរនៅក្ដារធំ ឲ្យសិស្សតែង ៗ

សាសនសុភាសិតទាំងពីរថ្នាក់ដូចមានខាងក្រោមនេះ

---

ប្រយោគទី ១

## សាសនសុភាសិត

ធម្មវិន័យថ្នាក់ត្រី

ថ្ងៃទី ១៦ ខែធ្នូ ២៤៩៥/១៩៥២

បដិគច្ចេវ តំ កយិរា យំ ជញ្ញា ហិតមត្តនោ

ដឹងថាកម្មណាជាប្រយោជន៍ដល់ខ្លួន គួរប្រញាប់ប្រញាល់ធ្វើនូវកម្មនោះឲ្យបានមុនគេ ៗ

ចូរអធិប្បាយភាសិតនេះឲ្យសមហេតុផល ព្រមទាំងលើកយកភាសិតឯទៀតមកប្រកបជាមួយផង តែត្រូវបញ្ចូលសេចក្ដីនៃភាសិតនោះឲ្យសមតាមសេចក្ដីនៃភាសិតដើម ៗ

---

# ប្រយោគទី ១

## សាសនសុភាសិត

ធម្មវិន័យ ថ្នាក់ទោ

ថ្ងៃទី ១៦ ខែធ្នូ ២៤៩៥/១៩៥២

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

យសតែងចំរើនដល់អ្នកមានព្យាយាមរឿសរើ ១, អ្នកមានស្មារតី ១, អ្នកមានការងារស្អាត ១, អ្នកមានប្រក្រតីពិចារណារួចទើបធ្វើ ១, អ្នកប្រុងប្រយ័ត្ន ១, អ្នកមានប្រក្រតីរស់នៅដោយធម៌ ១, អ្នកមិនប្រមាទ ១ ។

ចូរអធិប្បាយភាសិតនេះឲ្យសមហេតុផល ព្រមទាំងលើកយកភាសិតឯទៀតមកប្រកបជាមួយផង តែត្រូវបញ្ចូលសេចក្ដីនៃភាសិតនោះឲ្យសមតាមសេចក្ដីនៃភាសិតដើម ។

---

ម៉ោង ៨ យប់ និមន្តព្រះវិន័យធរ ឯក-ញឹម នឹងព្រះអាចារ្យ សុខ-សាន្ត សំដែងធម៌ទេសនាបុច្ឆា-វិសជ្ជនា, បន្ទាប់ពីនោះ ក្រុមកង ឯកទេសប្រគំតូរ្យតន្ត្រី នឹង៖ ច្រៀងចំរៀងជាតិជាច្រើនបទ ។

ថ្ងៃទី ៣.– គឺថ្ងៃ ២ កើតខែបុស្ស (១៧-១២-៥២) ម៉ោង ៨ ព្រឹក ជួបជុំសិស្សដូចមុន អធិបតីបើកប្រយោគទី ២ គឺបញ្ហាវិនយប្បញ្ញត្តិថ្នាក់ត្រី-ទោ ៥ ១ ឲ្យសិស្សសរសេរឆ្លើយ, ដូចមានខាងក្រោមនេះ

# ប្រយោគទី ២

## បញ្ហាវិន័យប្បញ្ញត្តិ

ធម្មវិន័យ ប្អាក់ត្រី

ថ្ងៃទី ១៣ ខែធ្នូ ២៤៩៥ / ១៩៥២

១.– ចុះពាក្យថាវិន័យ តើបានសេចក្តីដូចម្តេច? មានប៉ុន្មានយ៉ាង? អ្វីខ្លះ? អ្នកដែលប្រព្រឹត្តកាន់តាមច្បាប់វិន័យ តើមានប្រយោជន៍ដូចម្តេច?

២.– ចុះបាតិមោក្ខសំវរសីល តើសម្រេចដោយចេតសិកណា? បានជាសម្រេចដោយចេតសិកនោះ តើព្រោះហេតុអ្វី?

៣.– ភិក្ខុទទួលស្ករ, តែ, កាហ្វេ, ទុកឲ្យកន្លង៧ថ្ងៃទៅ ហើយយកតែដែលខ្លួនទទួលទុកនោះមកឆាន់ ដោយអាងថាខ្លួនឈឺ តើត្រូវអាបត្តិអ្វី?

៤.– ចុះភិក្ខុប្រើប្រាស់ចីវរប្បច្ច័យ តើមានប្រយោជន៍ប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

៥.– ភិក្ខុធ្វើវេជ្ជកម្ម តើគួរធ្វើដល់បុគ្គលបែបណា? មិនគួរធ្វើដល់បុគ្គលបែបណា? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

# ប្រយោគទី ២

## បញ្ហាវិនយប្បញ្ញត្តិ

### ធម្មវិន័យ ថ្នាក់ទោ

ថ្ងៃទី ១៣ ខែធ្នូ ២៤៩៥ / ១៩៥២

១.- សិក្ខាបទដូចម្តេចខ្លះ ហៅថាសិក្ខាបទក្រៅបាតិមោក្ខ? ព្រះអង្គទ្រង់បញ្ញត្ត អនុញ្ញាតសិក្ខាបទទាំងនោះបន្ថែមមកទៀត តើទ្រង់យល់ឃើញប្រយោជន៍ដូចម្តេច? ចូរអធិប្បាយ ។

២.- ភិក្ខុឆាន់សាច់មិនបានពិចារណា ឲ្យស្គាល់ថាជាសាច់នេះសាច់នោះ តើត្រូវអាបត្តិអ្វី?

៣.- ភិក្ខុប្រើប្រាស់ចីវរដាច់បិទបាំងអវយវៈមិនជិត ហើយដើរទៅកាន់ស្រុក តើត្រូវអាបត្តិអ្វី?

៤. ចុះអតិសមាចារៈ បានសេចក្តីដូចម្តេច? ចូរអធិប្បាយ ។

៥.- សទ្ធិវិហារិក មិនប្រកបដោយធម៌អ្វីខ្លះ ដែលឧបជ្ឈាយ៍បណ្តេញចេញពីវត្ត? បើឧបជ្ឈាយ៍បណ្តេញចេញហើយ តើត្រូវប្រព្រឹត្តដូចម្តេចទៀត ដើម្បីកុំឲ្យត្រូវអាបត្តិទុក្កដ? ។

---

ម៉ោង ៣ រសៀល អធិបតីបើកប្រយោគទី ៣ គឺធម្មបញ្ហាថ្នាក់ត្រី-ទោ ៥១ ឲ្យសិស្សសរសេរឆ្លើយ, ដូចមានសេចក្តីខាងក្រោមនេះ

## ប្រយោគទី ៣

## ធម្មប្បញ្ហា

### ធម្មវិន័យ ថ្នាក់ត្រី

ថ្ងៃទី ១៣ ខែធ្នូ ២៤៩៥/១៩៥២

១.- ចុះសទ្ធាបានសេចក្ដីដូចម្ដេច? ព្រោះហេតុអ្វីបានជាសទ្ធានេះបើមាននៅក្នុងក្រមធម៌ណា សុទ្ធតែនៅក្នុងទី ១ ឬនៅខាងដើមក្រមធម៌នោះជាដរាប? ចូរអធិប្បាយ ។

២.- បុណ្យនិងបាប បើមិនបាច់កសាងសោះទេ តើឲ្យផលឬមិនឲ្យ? បើឲ្យផល តើឲ្យដូចម្ដេច? ចូរអធិប្បាយ ។

៣.- អប្បមាទៈ និងសតិ ធម៌ទាំងពីរនេះបានសេចក្ដីដូចម្ដេច? មានសេចក្ដីប្លែកគ្នាដូចម្ដេច?

៤.- ព្រះពុទ្ធសាសនា ដែលចំរើនរុងរឿងទៅបាន តើដោយអាស្រ័យបរិស័ទប៉ុន្មានពួក? អ្វីខ្លះ? បរិស័ទទាំងនោះ តើប្រកបដោយធម៌ប៉ុន្មានយ៉ាង? អ្វីខ្លះ?

៥.- ប្រទេសដូចម្ដេចហៅថាបដិរូបទេស (ប្រទេសសមគួរ)? សំដៅយកប្រទេសណា? អ្នកនៅក្នុងប្រទេសនោះ តើមានសេចក្ដីចំរើនដូចម្ដេច?

## ប្រយោគទី ៣

# ធម្មប្បញ្ញា

ធម្មវិន័យ ថ្នាក់ទោ

ថ្ងៃទី ១៧ ខែធ្នូ $\frac{២៤៩៥}{១៩៥២}$

១.– វត្ថុទាំងពួងសុទ្ធតែមានគ្រឿងដុសខាត់ឲ្យស្អាតទាំងអស់, ចុះចិត្តរបស់មនុស្ស តើមានធម៌អ្វី ជាគ្រឿងដុសខាត់ឲ្យបរិសុទ្ធ? ហៅថាធម៌អ្វី? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

២.– ការសិក្សាក្នុងពុទ្ធសាសនា តើចែកចេញទៅជាប៉ុន្មានថ្នាក់? អ្វីខ្លះ? អ្នកដែលកំពុងសិក្សា តើហៅថាអ្វី? មានប៉ុន្មានពួក? អ្នកដែលសិក្សារួចហើយ តើហៅថាអ្វី? មានប៉ុន្មានពួក?

៣.– វិញ្ញាណ នឹងផស្សៈ ទាំងពីរនេះ តើកើតឡើងដោយអាស្រ័យអ្វី? មានកិច្ចផ្សេងគ្នាដូចម្ដេច?

៤.– មេត្តានឹងករុណា ទាំងពីរនេះមានសេចក្ដីផ្សេងគ្នាដូចម្ដេច? ចូរអធិប្បាយ ។

៥.– កុសលធម៌ទាំងពួង ដែលបានចំរើន លូតលាស់ឡើងជាលំដាប់ តើអាស្រ័យមកពីធម៌អ្វីជាជំនួយ? ចូរអធិប្បាយធម៌នោះឲ្យល្មមស្ដាប់បានមកផង ។

ម៉ោង ៨ យប់និមន្តលោកគ្រូចៅអធិការ ពុធ-ប៉ុណ្ណ វត្តខេមរាម៉ុសេង (គណៈធម្មយុត្តិ) សំដែងធម៌ទេសនា ។

ថ្ងៃទី ៤.- គឺថ្ងៃ ៣ កើតខែបុស្ស (១៨-១២-៥២) ម៉ោង ៨ ព្រឹក ជួបជុំសិស្សដូចមុន អធិបតីបើកប្រយោគទី ៤ គឺបញ្ហាពុទ្ធប្បវត្តិនិងប្រស្នាអនុពុទ្ធប្បវត្តិថ្នាក់ត្រី-ទោ ៥ ១ ឲ្យសិស្សសរសេរឆ្លើយ. ដូចមានខាងក្រោមនេះ

ប្រយោគទី ៤

បញ្ហាពុទ្ធប្បវត្តិ

ធម្មវិន័យ ថ្នាក់ត្រី

ថ្ងៃទី ១៨ ខែធ្នូ ២៤៩៥/១៩៥២

១.- ព្រះសម្មាសម្ពុទ្ធកាលបានត្រាស់ដឹងដំបូងថ្មីៗ តើព្រះអង្គទ្រង់សំដែងធម៌អ្វី? ធម៌នោះបានសេចក្តីដូចម្តេច? ហៅថាវចនៈអ្វី? ទ្រង់សំដែងឲ្យអ្នកណាស្តាប់?

២.- ព្រះពុទ្ធបាត់ជាបុព្វការីយ៉ាងវិសេស តើពុទ្ធមាមកជនត្រូវតបឧបការៈដល់ព្រះអង្គដោយវិធីបែបណា? ចូរអធិប្បាយ ។

៣.— ចុះព្រះអង្គទ្រង់ប្រសូតនៅទីណា? ថ្ងៃ-ខែ-ឆ្នាំណា? រាប់តាំងពីនោះមកទល់នឹងថ្ងៃ-ខែ-ឆ្នាំដែលប្រឡងនេះ តើបានប៉ុន្មានឆ្នាំហើយ?

៤- ចុះព្រះអង្គស្ដេចយាងទៅ ចូលបរិនិព្វានក្នុងនគរទីណា? ទ្រង់យល់ឃើញដូចម្ដេច បានជាស្ដេចទៅចូលបរិនិព្វានក្នុងនគរនោះ?

៥.— ចុះលោកណាជាប្រធាន ក្នុងការចែកព្រះបរមសារីរិកធាតុ? ចែកទៅនគរណាខ្លះ? អ្នកមេចំណែកនោះ តើមានបានអ្វីនឹងគេដែរឬទេ?

---

## ប្រយោគទី៤

## ប្រស្នាអនុពុទ្ធប្បវត្តិ

ធម្មវិន័យ ថ្នាក់ទោ

ថ្ងៃទី ១៨ ខែធ្នូ ២៤៩៥/១៩៥២

១. ចុះអនុពុទ្ធ សំដៅយកលោកដែលមានសភាពដូចម្ដេច? បុរស ឬស្ត្រី គ្រហស្ថ ឬបព្វជិត?

២.— បណ្ដាសាវ័កទាំងអស់ តើសាវ័កណាដែលជាចំបងលើសាវ័កឯទៀតៗ? សាវ័កនោះតើលោកមានសណ្ដាប់ធ្នាប់នឹងធ្វើប្រយោជន៍ទុកដល់ពុទ្ធសាសនិកជនជាន់ក្រោយឲ្យយកគម្រាប់បានឬដូចម្ដេចខ្លះ?

៣.– ចុះព្រះអានន្ទលោកមានអគ្គដ្ឋានជាអ្វី? មានឯតទគ្គៈខាងអ្វី? លោកមានគុណបំណាច់ដល់ពុទ្ធសាសនិកជនដូចម្ដេចខ្លះ?

៤.– ចុះអនុពុទ្ធអង្គណាមុនបរិនិព្វាន លោកបានសំដែងធម៌ថ្វាយព្រះបរមគ្រូស្ដាប់? ធម៌ដែលលោកសំដែងនោះ តើមានសេចក្ដីដូចម្ដេច?

៥.– ចុះអគ្គសាវ័កទាំងពីរស្ដាំឆ្វេង លោកមានគុណធម៌ទឹងមានប្រយោជន៍ដល់យើងដូចម្ដេចខ្លះ? ក្នុងពេលដែលគេនាំព្រះសារីរិកធាតុរបស់លោក មកដំកល់ទុកក្នុងប្រទេសយើងរវាង ៦ ថ្ងៃ តើនាំបណ្ដាលឲ្យទឹកចិត្តរបស់ពុទ្ធសាសនិកជនប្លែក ព្រមទាំងឲ្យមានគំនិតយល់ឃើញដូចម្ដេចខ្លះ? ចូរអធិប្បាយ ។

---

ម៉ោង ១១ ប្រជុំពួកក្រុមមេប្រយោគ សិស្ស ឧបាសក ឧបាសិកា ថតរូបនៅទីសាលាបាលី, សាលាធម្មវិន័យ, បរិវេណវិហារ, មន្ទីរឃោសនាការ, ទុកជាអនុស្សាវរីយ៍ក្នុងពិធីបុណ្យប្រឡងធម្មវិន័យ ។

ម៉ោង ១១ កន្លះ អង្គាសចង្ហាន់ដល់ភិក្ខុសាមណេរជាង ២០០ អង្គ ។

ម៉ោង ៣ រសៀល ក្រុមមេប្រយោគ ចាត់ចែងធ្វើការប្រមូលសំណុំរឿងប្រឡងនឹងសេចក្ដីកត់ហេតុផ្សេងៗ ព្រមទាំងចុះហត្ថលេខា ។

ម៉ោង ៧ ជួបជុំក្រុមមេប្រយោគ នឹងសិស្សជាង ២០០ រូប ព្រមទាំងឧបាសក ឧបាសិកាជាច្រើនកុះករណាស់ណាន់តាន់តាប់ រួចសូត្រ

ធម៌ជ័យ នៅជូនពរសព្ទសាធុការដល់ឥស្សរជនទាំងឡាយ មានលោកវរសេនីយ៍ត្រី ព្រមទាំងពួកពុទ្ធបរិស័ទទាំងឡាយ, បន្ទាប់ពីនោះ ព្រះមហាឧត្តមវិជ្ជា កែ អឿន ថ្លែងបាឋកថាជូនពរសព្ទសាធុការទឹងសេចក្ដីអំណរដល់ឥស្សរជនទាំងឡាយ ព្រមទាំងពុទ្ធបរិស័ទដែលបានជួយឧបត្ថម្ភក្នុងការប្រឡងនេះ, ក្រោយមក ទើបលោកវរសេនីយ៍ត្រី ឈួន-ម្ជុលពេជ្រ ថ្លែងបាឋកថាតបមកវិញ ទឹងដាស់តឿនដល់ព្រះសង្ឃឲ្យខំរៀនសូត្រធម្មវិន័យ ទឹង ដាស់តឿនដល់ប្រជាជនទាំងឡាយ ឲ្យមានសាមគ្គីធម៌ ។

ម៉ោង ៨ កន្លះ និមន្តព្រះអាចារ្យឈឹន-ញូង សំដែងធម៌ទេសនា១ ចប់ ពួកគងឯកទេសលេងល្ខោនជាតិ ទឹងបញ្ចាំងកុនជូនបងប្អូនរួមជាតិមើល ។

ប្រឡងធម្មវិន័យក្នុងពេលនេះ ក្រសួងធម្មការទឹងក្រសួងសម្ដេចព្រះសង្ឃនាយក បានតាំងអធិបតីមេប្រយោគដូចមានខាងក្រោមនេះ

១.– ព្រះសុមង្គលសីលាចារ្យមេគណ វត្តដំណាក់ ជាអធិបតី

២. ព្រះមហាឧត្តមវិជ្ជា កែ-អឿន ជួសអនុគណវត្តព្រះព្រហ្មរតន៍ ជាសមាជិក

៣.– ព្រះសុធម្មបញ្ញា ចាប ពៅ វត្តស្វាយ "

៤.– ព្រះវិន័យធរគណ ឈិត តក វត្តដំណាក់ "

៥.– លេខាធិការគណ ម៉ាន់ ឡាយ វត្តដំណាក់ ជាលេខាធិការ អធិបតីបានតាំងសមាជិក ១ ក្រុមទៀត ដើម្បីជួយត្រួតត្រាតាមបន្ទប់ប្រឡង គឺ :

១.– ព្រះវិន័យធរអនុគណ ឯក ញឹម ជាសមាជិក

២.– ព្រះអាចារ្យ សុខ សាន្ត " "

៣.– ព្រះអាចារ្យ គោ-ឈួន " "

៤.– ព្រះអាចារ្យ លិវ-លន " "

ក្នុងរោងបុណ្យប្រឡងធម្មវិន័យប៉ុន្មានថ្ងៃនេះ លោកវរសេនីយ៍ត្រី ឈួន-ម្ជុលពេជ្រ បានអំណោយរថយន្តធំ ៣ គឺរថយន្ត ២ សម្រាប់ដឹកឧស រថយន្ត ១ សម្រាប់ដឹកមនុស្សមកពីទីឆ្ងាយ ព្រមទាំងវត្តផ្សេងៗ មានអគ្គិរដ្ឋាដើម ទីងបរិច្ចាគហិរញ្ញវត្ថុ ១៥០០ រៀល, លោកយាយ យ៉ឹម ជាមាតាលោកវរសេនីយ៍ត្រី បានបរិច្ចាគហិរញ្ញវត្ថុ ៥០០ រៀល, សាលាខេត្តបានអំណោយរថយន្តធំ ១ សម្រាប់ដឹកមនុស្សទីងវត្តផ្សេងៗ ដែរ ព្រមទាំងហិរញ្ញវត្ថុ ២០០ រៀល, ឧបាសក ឃ្លោក អេង ឧបាសិកា ជួយ បរិច្ចាគហិរញ្ញវត្ថុ ៣០០០ រៀល, ដំកល់ទុកឧបត្ថម្ភកងការប្រឡង ព្រមទាំងក្រសួងរាជការគ្រប់តម្លៃង ទីងពុទ្ធបរិស័ទជិតឆ្ងាយ បានជួយឧបត្ថម្ភ ក្នុងបុណ្យប្រឡងនេះ ជាបដល់រួចកិច្ចប្រឡង ។

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

## របស់ក្រសួងធម្មការ

(តមក)

---

សញ្ញាប័ត្រលេខ ៨៧៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ម-ហាន់ នាមឆាយា ហានុវិជ្ជា កើតឆ្នាំជូត អាយុ ៤៩ វស្សា ២៦ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៧៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សន-ឡោម នាមឆាយា ឡោមសិរី កើតឆ្នាំថោះ អាយុ ២៣ វស្សា ៤ ជាចៅអធិការ វត្តសំសាន ឃុំកាលោ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៧៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យិម-ង៉ាក់ នាមឆាយា ញាណសរោ កើតឆ្នាំថោះ អាយុ ២៣ វស្សា ៤ ជាគ្រូសូត្រស្តាំ វត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៧៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញែម-សាត នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំថោះ អាយុ ២៣ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៧៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ដោក ថោង នាមឆាយា ចន្ទសារោ កើតឆ្នាំរោង អាយុ ៣៤ វស្សា ១៣ ជាចៅអធិការវត្តកាលោ ឃុំ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៨០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យស់-ពោង នាមឆាយា គ្មាន .. កើតឆ្នាំវក អាយុ ៣០ វស្សា ១១ ជាចៅអធិការវត្តបឹងខ្មោរ ឃុំស្វាយដូនកែវ ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-ទេព នាមឆាយា ធម្មសុវណ្ណ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាចៅអធិការវត្តចន្ទរង្សី ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ តឹម-រឹង នាមឆាយា គ្មាន... កើតឆ្នាំខាល អាយុ ២៤ វស្សា ៣ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែន-ចេង នាមឆាយា ចន្ទជោត កើតឆ្នាំថោះ អាយុ ២៣ វស្សា ៣ ជាគ្រូសូត្រឆ្វេង វត្ត ឃុំ ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-សេង នាមឆាយា ញាណជោត កើតឆ្នាំជូត អាយុ ៣៧ វស្សា ១២ ជាគ្រូសូត្រស្តាំ វត្តស្វាយដូនកែវ ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ តាប-ធិរ នាមឆាយា ចន្ទសុវណ្ណ កើតឆ្នាំរកា អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

(មានត)